ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២០ លេខ ២ ខែមិថុនា ២០១៦ តម្លៃ ១.៥០០៛

# វិទ្យាល័យនៅកម្ពុជា៖ កង្វះខាតការស្រាវជ្រាវ

## ខ្លឹមសារសង្ខេប

ការឡើងឋានៈជាប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតទាប ជាដំណាក់កាលដ៏សំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច នៅកម្ពុជា។ ការផ្លាស់ប្ដូរគោលនយោបាយ ដែលធ្លាប់តែផ្ដោតលើការកាត់បន្ថយភាពក្រីក្រ ទៅផ្ដោតជាសំខាន់លើកំណើនសម្រាប់ទាំងអស់គ្នា ប្រកបដោយចីរភាពដោយមានកម្លាំងជំរុញពីសហគ្រាសបង្កើតតម្លៃបន្ថែមខ្ពស់ បញ្ជាក់ឱ្យឃើញថា ការអប់រំ និងបណ្ដុះបណ្ដាលជំនាញ កាន់តែមានសារៈសំខាន់ឡើង។ ដោយសារចំណែកថវិកាជាតិសម្រាប់វិស័យអប់រំកាន់តែកើនឡើង ហើយការប្ដេជ្ញាចិត្តផ្នែកនយោបាយក៏កាន់តែខ្ពស់ បូករួមទាំងជំនួយផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុជាបន្តបន្ទាប់ពីដៃគូអភិវឌ្ឍន៍ផង កម្ពុជានាបច្ចុប្បន្នបានឈានដល់ពាក់កណ្ដាលផ្លូវនៃ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-១៨ ដែលមានគោលដៅធានាឲ្យបាននូវការអប់រំមួយមានគុណភាពល្អ ហើយមនុស្សគ្រប់គ្នាមានលទ្ធភាពទទួលបានការអប់រំនេះយ៉ាងងាយស្រួល។ ទោះយ៉ាងនេះក្ដី បញ្ហាប្រឈមនៅតែមានច្រើននៅឡើយ។ ការសិក្សាជាក់ស្ដែងមួយចំនួនពីការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ព្រមទាំងព័ត៌មានលំអិតពីសន្និបាតអប់រំឆ្នាំ២០១៦ បានបង្ហាញពីកង្វះខាតការស្រាវជ្រាវលើបួនចំណុចសំខាន់ៗ៖ ១) គុណភាពនៃការអប់រំ ២) កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ៣) ការបង្រៀនឯកជន ឬការបង្រៀនគួរ និង ៤)ការអភិវឌ្ឍខ្លួន សុខភាព និងសីលធម៌របស់សិស្ស។




*ការអប់រំ និងការបណ្ដុះបណ្ដាលជំនាញ មានសារៈសំខាន់ខ្លាំងណាស់។*
*ខេត្តព្រៃវែង ខែកុម្ភៈ ឆ្នាំ២០១៦*

## សេចក្ដីផ្ដើម

ប្រព័ន្ធអប់រំទូទៅនៅកម្ពុជា ចែកចេញជា៤ដំណាក់កាល៖ មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា (បឋមភូមិ និងទុតិយភូមិ) និងឧត្តមសិក្សា។ ក្រោយបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) សិស្សអាចជ្រើសរើសបន្តការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) ឬអាចចូលរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង ក្រសួងអប់រំ យុវជន និងកីឡា នៅតាមបណ្ដាខេត្តមួយចំនួន។

ចក្ខុវិស័យអប់រំរយៈពេលវែង គឺធ្វើឲ្យគុណភាពអប់រំគ្រប់កម្រិតបានកាន់តែល្អប្រសើរឡើង។ រាជរដ្ឋាភិបាលបានបង្កើនថវិកាជាតិសម្រាប់វិស័យអប់រំជាបន្តបន្ទាប់ ពី ១៦% នៃចំណាយសាធារណៈសរុបក្នុងឆ្នាំ២០១២ ដល់ ១៧% ក្នុងឆ្នាំ២០១៥ និងជាង ១៨,៥% ក្នុងឆ្នាំ២០១៦ (MOEYS 2016)។ ដោយប្រៀបធៀបទៅនឹងវត្ថុបំណងទាំងបីនៃ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ២០១៤-១៨ ពោលគឺ លទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ គុណភាពនិងភាពសមស្របនឹងតម្រូវការនៃ

---

អត្ថបទនេះ រៀបចំដោយ សូ ភីណា អ្នកស្រាវជ្រាវ និង Ji-Hyun Kang អ្នកស្រាវជ្រាវស្ម័គ្រចិត្ត (មកពី KOICA) នៃផ្នែកអប់រំ នៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា៖ So Phina and Ji-Hyun Kang. 2016. “Upper Secondary School in Cambodia: Research Gaps.” Cambodia Development Review 20(2): 1-5។ ភ្នំពេញ វិទ្យាស្ថាន CDRI។

## មាតិកា

វិទ្យាល័យនៅកម្ពុជា៖ កង្វះខាតការស្រាវជ្រាវ ........................ ១
អភិបាលកិច្ចទឹកសម្រាប់ភាពធន់នឹងអាកាសធាតុ៖
លទ្ធផលសិក្សាពីថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ............ ៦
ប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថាន៖ បទពិសោធន៍
ទទួលបានពីគម្រោងសាកល្បងនៃកម្មវិធីរេដ+............... ១០
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ...................... ១៥
— ស្ថានភាពក្នុងប្រទេស........................ ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........................................ ២៤

រូបភាព១៖ រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំនៅកម្ពុជា




ប្រភព៖ ADPC 2008

ការបង្រៀននិងការរៀន និង ការកែលំអការដឹកនាំនិងគ្រប់គ្រងលើវិស័យអប់រំនោះ សន្និបាតអប់រំឆ្នាំ២០១៦ បានរាយការណ៍ពីការរីកចម្រើនមួយចំនួន នៅកម្រិតមធ្យមសិក្សាក្នុងសូចនាករស្នូលដូចខាងក្រោម (តារាង១)។

ទោះបីមានការប្តេជ្ញាចិត្តពីរាជរដ្ឋាភិបាល និងជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាក្តី ឧបសគ្គធំៗមួយចំនួននៅតែមាន។ សន្និបាតអប់រំឆ្នាំ២០១៦ បានទទួលស្គាល់ថា មានបញ្ហាប្រឈម១១មុខ ចាប់ពី បញ្ហាផ្នែកគ្រប់គ្រងរដ្ឋបាលនិងបុគ្គលិក រហូតដល់ បញ្ហាផ្នែកហេដ្ឋារចនាសម្ព័ន្ធ ហិរញ្ញវត្ថុនិងផែនការ ការអភិវឌ្ឍកម្មវិធីសិក្សា និងការធានាគុណភាពអប់រំ។ ម៉្យាងទៀត អត្រាដ៏ខ្ពស់នៃសិស្សធ្លាក់ការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤-១៥ បានបង្ហាញថា ការអប់រំថ្នាក់មធ្យមសិក្សា កំពុងតែខ្វះគុណភាពជាខ្លាំង។ ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡា (MOEYS 2016) បានរាយការណ៍ពីការល្អប្រសើរឡើងតែបន្តិចបន្តួចក្នុងអត្រាចុះឈ្មោះចូលរៀនថ្នាក់មធ្យមសិក្សាទុតិយភូមិ គុណភាពនៃការរៀន និងអត្រាត្រួតថ្នាក់ រីឯអត្រាសិស្សបោះបង់ការសិក្សានៅនឹងដដែល។

អត្ថបទនេះ ពិនិត្យលើការសិក្សាដែលផ្អែកលើការពិសោធន៍ជាក់ស្តែងមួយចំនួនស្តីពី ការអប់រំថ្នាក់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជា និងព្យាយាមកំណត់នូវចន្លោះខ្វះខាតសំខាន់ៗក្នុងការស្រាវជ្រាវ។ លទ្ធផលរកឃើញទាំងនេះអាចជួយផ្តល់ព័ត៌មានដល់របៀបវារៈនៃការស្រាវជ្រាវថ្នាក់ជាតិ និងការកំណត់អាទិភាពក្នុងវិស័យអប់រំ ហើយក៏អាចដាក់បញ្ចូលទៅក្នុងកំណែទម្រង់វិស័យអប់រំនាពេលអនាគតដែរ។ អត្ថបទនេះចាប់ផ្តើមឡើងតាមការ

តារាង១៖ សូចនាករស្នូលនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-១៨

| សូចនាករស្នូល | ស្ថានភាពឆ្នាំ ២០១៣/១៤ | ស្ថានភាពឆ្នាំ ២០១៥/១៦ | គោលដៅឆ្នាំ ២០១៧/១៨ |
|---|---|---|---|
| *គោលនយោបាយ ផ្នែកទី១៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌* | | | |
| ចំនួនខេត្តមានអត្រាបញ្ចប់ការអប់រំថ្នាក់អនុវិទ្យាល័យស្មើឬលើសពី ៤០% | ៧ | ៨ | ១៧ |
| *គោលនយោបាយ ផ្នែកទី២៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ* | | | |
| អត្រាអក្ខរកម្មនៃយុវជន (១៥-២៤ឆ្នាំ) | ៩២,១% (២០១២) | ៩០,១% (២០១៤) | ៩៧,៥% |
| ការវាយតម្លៃថ្នាក់ជាតិលើការរៀនសូត្ររបស់សិស្សថ្នាក់ទី៣ ទី៦ និងទី៨ សម្រាប់ ភាសាខ្មែរ និងគណិតវិទ្យា | សិស្សថ្នាក់ទី៣ ការវាយតម្លៃ បានអនុវត្តរួច | សិស្សថ្នាក់ទី៦ លទ្ធផលវាយតម្លៃបានផ្សព្វផ្សាយរួច | សិស្សថ្នាក់ទី៨ ការវាយតម្លៃនឹងត្រូវអនុវត្ត |

ប្រភព៖ សន្និបាតអប់រំឆ្នាំ២០១៦

ពិនិត្យលើចំណុចត្រូវស្រាវជ្រាវចំនួនបួន៖ ១) គុណភាពអប់រំ និងគ្រូបង្រៀន ២) ខ្លឹមសារកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ៣) ការបង្រៀនឯកជន ឬបង្រៀនគួរ និង ៤) កម្មវិធីសុខភាពសាលារៀន។ បន្ទាប់មក មានការលើកមតិពីទិសដៅសម្រាប់ការស្រាវជ្រាវនាពេលអនាគត ដោយផ្តល់ជាសំណួរគួរស្រាវជ្រាវមួយចំនួន។

## ការសិក្សាលើឯកសារសិក្សាស្រាវជ្រាវមានស្រាប់ *គុណភាពនៃការអប់រំ និងការបង្រៀន*

ដោយសារ ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស ដែលជាកត្តាមួយជួយសម្រួលដល់ការចូលបម្រើការងារ មានគុណភាពកាន់តែល្អប្រសើរឡើង ដូច្នេះវាក៏បង្កើតកម្លាំងពលកម្មជំនាញមានគុណវឌ្ឍិ បានកាន់តែច្រើនឡើង។ ការបង្កើនគុណភាពអប់រំគឺជាប្រធានបទស្នូលមួយ នៃការស្រាវជ្រាវក្នុងវិស័យអប់រំជាយូរណាស់មកហើយ។ អត្រាដ៏ទាបនៃការប្រឡងជាប់របស់សិស្សថ្នាក់ទី១២ ក្នុងការប្រឡងថ្នាក់ជាតិឆ្នាំ២០១៤-១៥ (២៦%) ជាលទ្ធផលមួយនៃការចាប់ផ្តើមអនុវត្តវិធានការដ៏តឹងរឹង ដើម្បីលុបបំបាត់ការចម្លងគ្នាក្នុងពេលប្រឡង និងអំពើពុករលួយនានា ហើយវាក៏ជាភស្តុតាងច្បាស់ក្រឡែតមួយ បង្ហាញពីគុណភាពខ្សោយនៃប្រព័ន្ធអប់រំថ្នាក់មធ្យមសិក្សា (Madhur 2015)។ ដោយមើលឃើញពី តម្រូវការកិច្ចប្រឹងប្រែងពង្រឹងគុណភាពអប់រំបន្ថែមទៀត លោក Khieng, Madhur and Chhem (2015) បានស្នើឲ្យយកចិត្តទុកដាក់កាន់តែខ្លាំងលើ ការបង្កើនអត្រាចុះឈ្មោះចូលរៀន ការកាត់បន្ថយអត្រាបោះបង់ការសិក្សា ការទាក់ទាញគ្រូបង្រៀនដែលមានគុណភាព ការពង្រឹងផ្នែកគរុកោសល្យ និងការកែលំអការគ្រប់គ្រងនិងអភិបាលកិច្ចក្នុងសាលារៀន។

គុណភាពនៃប្រព័ន្ធអប់រំរបស់ប្រទេសមួយ មិនអាចនឹងប្រសើរឡើងបានដោយមិនគិតពីបញ្ហាគុណភាពគ្រូបង្រៀននោះទេ។ ការស្រាវជ្រាវពីថ្នាក់មធ្យមសិក្សាទុតិយភូមិជាច្រើន បានគូសបញ្ជាក់ពីបញ្ហាប្រឈមនៃកង្វះចំនួន និងគុណភាពគ្រូបង្រៀន (Brehm and Silova 2014; Madhur 2014; MOEYS 2016; Nou 2015; Phin 2014; You 2010)។ ទោះបីក្រសួងអប់រំ យុវជន និងកីឡា បានប្តេជ្ញាចិត្ត និងប្រឹងប្រែងជាខ្លាំងក្នុងការពង្រឹងវិស័យអប់រំយ៉ាងណាក្តី ក៏គ្រូបង្រៀនថ្នាក់មធ្យមសិក្សាទុតិយភូមិនៅមានកម្រិតអប់រំទាបនៅឡើយ ហើយចំនួនគ្រូនៅតាមសាលារៀនជនបទ នៅតែមានការខ្វះខាតបើប្រៀបនឹងសាលារៀននៅទីក្រុង (Nou 2015)។ កង្វះខាតគ្រូបង្រៀនមានការបណ្តុះបណ្តាលត្រឹមត្រូវ អាចជះឥទ្ធិពលធ្ងន់ធ្ងរទៅលើសិស្សក្រីក្រ ដែលមិនមានចំណេះដឹងគ្រប់គ្រាន់ សម្រាប់បន្តការសិក្សាថ្នាក់ឧត្តមសិក្សា ហើយទីបំផុត ធ្លាក់ចូលក្នុងវដ្តនៃការអប់រំមានគុណភាពទាប ពីមួយជំនាន់ទៅមួយជំនាន់ (Madhur 2014)។ Un (2014) បានចង្អុលបង្ហាញថា ការអប់រំដែលមានគុណភាពខ្សោយ មិនមែនសុទ្ធតែបណ្តាលមកពីបញ្ហាកង្វះគ្រូបង្រៀននោះទេ ប៉ុន្តែក៏អាចមកពីគុណភាពគ្រូបង្រៀនផងដែរ។ អ្នកប្រាជ្ញជាច្រើន បានបន្ទុយការបន្ទោសគ្រូលើបញ្ហាគុណភាពបង្រៀន (Bray 2007; Dawson 2010) ដោយបែរទៅសង្កត់ធ្ងន់លើទំនាក់ទំនងរវាងគុណភាពគ្រូ និងជំនួយគាំទ្រពីស្ថាប័នសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការរៀនសូត្របន្ថែមរបស់គ្រូ (Phin 2014)។

ចក្ខុវិស័យក្រសួងអប់រំ យុវជន និងកីឡា (MOEYS 2013) សម្រាប់គ្រូបង្រៀនមានគុណភាពខ្ពស់ បានលើកពីចំណេះដឹងជំនាញ សមត្ថភាព និងចរិតលក្ខណៈគ្រូបង្រៀន ហើយបានកំណត់ឡើងវិញនូវអត្ថន័យនៃពាក្យ "ការបង្រៀន" ថាជា ជម្រើសអាជីពដ៏មានតម្លៃ និងគួរឲ្យគោរព។ យុទ្ធសាស្ត្រថ្មីៗសម្រាប់ជ្រើសរើស និងរក្សាទុកគ្រូបង្រៀន មានដូចជា ការព្យាយាមទាក់ទាញបុគ្គលល្អៗនិងវ័យឆ្លាតជាងគេឲ្យចូលធ្វើជាគ្រូបង្រៀន ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន និងការរៀបចំឡើងវិញនូវការអប់រំគ្រូ។ Tandon and Fukao (2015) បានផ្តល់មតិគាំទ្រឲ្យមានជាគោលនយោបាយស្រដៀងៗគ្នា ពោលគឺ ធ្វើឲ្យការបង្រៀនមានភាពទាក់ទាញ រៀបចំគ្រូបង្រៀនឲ្យកាន់តែមានប្រសិទ្ធភាព និងជំរុញឲ្យសកម្មភាពក្នុងថ្នាក់រៀនមានភាពកាន់តែប្រសើរឡើង។

ការសិក្សានានាបង្ហាញថា ការស្រាវជ្រាវមានសារៈសំខាន់ណាស់ ដើម្បីបង្កើនគុណភាពនៃការអប់រំបច្ចេកទេស និងកាត់បន្ថយកង្វះខាតជំនាញ។ ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៥-១៩ (MOEYS 2015) បានកំណត់ច្បាស់ពីតម្រូវការការស្រាវជ្រាវនៅក្នុង យុទ្ធសាស្ត្រសំដៅដាក់បញ្ចូលការអប់រំបច្ចេកទេស ទៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ ដើម្បីជួយរៀបចំសិស្សសម្រាប់ការចូលបម្រើការងារ។ លទ្ធផលនេះ ផ្អែកលើការសិក្សាពីមុនរបស់ Va (2012) ដែលរកឃើញថា ជម្រើសការអប់រំបច្ចេកទេសនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ បានកាត់បន្ថយកង្វះខាតជំនាញ អត្រាបោះបង់ការសិក្សា និងភាពក្រីក្រ ហើយបានលើកកម្ពស់ស្ថិរភាពសង្គម និងភាពត្រូវបានរាប់បញ្ចូលក្នុងសង្គម (inclusion)។ របាយការណ៍ទាំងពីរនេះ បានគូសបញ្ជាក់ពីបញ្ហាប្រឈមនៃ សម្ភារបរិក្ខារបច្ចេកទេសដែលមានតម្លៃខ្ពស់ និងការចំណាយដ៏ច្រើនលើការថែទាំសម្ភារទាំងនោះ ហើយបានលើកបន្ថែមថា ក្រសួងអប់រំ យុវជន និងកីឡា គួរវិនិយោគ និងពង្រីកផ្នែកជាច្រើនទៀត ជាពិសេស ការត្រួតពិនិត្យ និងការវាយតម្លៃការអប់រំដើម្បីកំណត់នូវសាលារៀន និងគ្រូដែលមានសកម្មភាពច្រើននិងល្អជាងគេ ក៏ដូចជាប្រព័ន្ធដែលទទួលបរាជ័យទាំងឡាយរបស់សាលារៀន។

### *ខ្លឹមសារកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន*

កម្មវិធីសិក្សា និងគរុកោសល្យល្អសមស្រប មានសារៈសំខាន់ណាស់សម្រាប់ធានាឲ្យបាននូវ គុណភាពអប់រំដែលតែងមានឥទ្ធិពលវិជ្ជមានទៅលើគុណភាពជីវិត (Un 2012)។ គោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥-០៩ បាននិយាយលំអិតពី ការផ្តល់កម្មវិធីសិក្សាសម្រាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ និងបឋមភូមិ ក្នុងគោលដៅ "បង្កើនទេពកោសល្យ និងសមត្ថភាពសិស្សទាំងអស់ឲ្យបានពេញលេញ ដើម្បីក្លាយជាពលរដ្ឋមានសមត្ថភាព ជាមួយនឹងការរីកលូតលាស់ស្របគ្នា និងមានតុល្យភាព ផ្នែកបញ្ញា ស្មារតី ចិត្តសាស្ត្រ និងរាងកាយ" (MOEYS 2004, 4)។ ដោយឡែក កម្មវិធីសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ មានគោលដៅផ្តល់ឲ្យសិស្សនូវ គ្រឹះដ៏រឹងមាំផ្នែក

អក្សរសាស្ត្រខ្មែរនិងគណិតវិទ្យា ការយល់ដឹងពីអត្តសញ្ញាណជាតិ និងបំណិនជីវិតដើម្បីអាចចូលរួមក្នុងជីវិតសហគមន៍ ព្រមទាំងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រទូទៅ និងវិទ្យាសាស្ត្រពិត និងជំនាញផ្នែកភាសាបរទេស (UNESCO 2008, 11)។ នាបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា កំពុងបង្កើតក្របខ័ណ្ឌថ្មីៗនៃកម្មវិធីសិក្សាថ្នាក់ជាតិសម្រាប់ការអប់រំទូទៅនិងផ្នែកបច្ចេកទេស ដែលគ្រោងនឹងផ្សាយចេញនៅចុងឆ្នាំ២០១៦។

ការស្រាវជ្រាវនានា បានបញ្ជាក់ពីសារៈសំខាន់នៃកំណែទម្រង់កម្មវិធីសិក្សា។ ដោយឡែក សព្វថ្ងៃនៅតែឃើញមានចន្លោះប្រហោងជាច្រើន រវាងគោលនយោបាយកម្មវិធីសិក្សា នឹងដំណើរការជាក់ស្តែងនៅក្នុងថ្នាក់រៀន។ សៀវភៅសិក្សាដែលជាធនធានស្នូលសម្រាប់ការបង្រៀន និងការរៀន ជាឧទាហរណ៍ជាក់ស្តែងមួយ។ ក្នុងការវិភាគលើខ្លឹមសារសៀវភៅសិក្សាសម្រាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ជាពិសេស ផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រ លោក Un (2014) បានចោទសំណួរជាច្រើនពីគុណភាព និងប្រសិទ្ធភាពនៃសម្ភារបង្រៀនទាំងនោះ។ ក្រៅពីកង្វះខាតផ្នែករូបវន្ត សៀវភៅសិក្សាមានទិសដៅសម្រាប់តែបណ្តុះការគិតរបស់សិស្សក្នុងកម្រិតទាបប៉ុណ្ណោះ រីឯវិធីសាស្ត្របង្រៀនវិញ ក៏មិនបានផ្តល់ឲ្យសិស្សនូវជំនាញដែលអាចរកការងារបានដូចជា ការគិតបែបវិភាគ ការធ្វើការងារជាក្រុម និងការដោះស្រាយបញ្ហាដែរ។ ដោយមូលហេតុនេះ សមត្ថភាពសិស្សនៅតែមិនអាចបំពេញបានតាមតម្រូវការរបស់និយោជក ហើយការសិក្សាជាច្រើនបានបញ្ជាក់ដូចគ្នាពី ភាពមិនស៊ីគ្នារវាងជំនាញរបស់សិស្សមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នឹងតម្រូវការរបស់និយោជក (ADB and ILO 2015; Khieng et al. 2015) ។ ដើម្បីកាត់បន្ថយបញ្ហាកង្វះខាតជំនាញ Davis (2005 cited in Nou 2015) បានបញ្ជាក់ពី តម្រូវការធ្វើស្តង់ដានីយកម្មការអប់រំថ្នាក់មធ្យមសិក្សា និងការគិតគូរឡើងវិញក្នុងការរៀបចំកម្មវិធីសិក្សា។

ដោយសារមានបញ្ហាប្រឈមទាំងនេះ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ២០១៤-១៨ បានបញ្ជាក់លំអិតពី កម្មវិធីអភិវឌ្ឍន៍សម្ភារបង្រៀននិងរៀនដ៏មាំទាំមួយ សំដៅកែលំអការអប់រំថ្នាក់មធ្យមសិក្សា និងថ្នាក់បច្ចេកទេស មានជាអាទិ៍ ការអភិវឌ្ឍកម្មវិធីសិក្សា ការផលិតនិងចែកចាយសៀវភៅសិក្សាគ្រប់មុខវិជ្ជាទៅតាមសាលាចំណេះទូទៅ និងការបង្កើតប្រព័ន្ធវាយតម្លៃមានស្តង់ដារច្បាស់លាស់សម្រាប់មុខវិជ្ជានីមួយៗ។

ទិដ្ឋភាពសំខាន់ពីរ ក្នុងវិស័យអប់រំដែលមិនសូវមានការស្រាវជ្រាវលើ គឺ ១) ការផ្លាស់ប្តូរពីគំនិតថា "គ្រូបង្រៀនជាឃ្លាំងចំណេះដឹង" ទៅជា "គ្រូបង្រៀនជាអ្នកបង្ហាត់បង្ហាញការរៀនសូត្រ" ហើយនិង ២) ការទាញយកអត្ថប្រយោជន៍ពីវគ្គសិក្សាតាមប្រព័ន្ធអ៊ិនធឺណិត (MOOCs) ដោយមិនមានការចំណាយអ្វី។ ការសិក្សាថ្មីៗមួយចំនួនបានពិភាក្សាពីតម្រូវការឲ្យ គ្រូបង្រៀនធ្វើការលើកទឹកចិត្តសិស្សឲ្យរៀនហួសពីសៀវភៅសិក្សា និងស្វែងរកចំណេះដឹងបន្ថែម (Ros and Chhem 2015; Chong 2013)។ ចំណុចនេះទាមទារការរៀបចំ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន អ្នកបង្ហាត់បង្ហាញការរៀនសូត្រ និងអ្នកជួយណែនាំទាំងឡាយ ដើម្បីផ្តល់នូវជំនាញដ៏ចាំបាច់មួយចំនួនសម្រាប់ការបង្រៀន និងជំរុញសិស្សឲ្យប្រើប្រាស់កម្មវិធី MOOC (Ros and Chhem 2015) ព្រោះបដិវត្តន៍ឌីជីថលកំពុងកែប្រែយ៉ាងលឿននូវការអប់រំក្នុងពិភពលោក ក្នុងសតវត្សទី២១ នេះ (Chhem 2016) ។

### *ការបង្រៀនគួរ*

ការស្រាវជ្រាវពីការបង្រៀនឯកជន ឬបង្រៀនគួរ ផ្តល់នូវគំនិតដ៏មានប្រយោជន៍អំពីទំហំ និងលក្ខណៈរបស់វា។ ការសិក្សាជាច្រើន (Bray 2007; Bray et al. 2016; Brehm and Silova 2014) បានពណ៌នាពី កំណើននិងតម្រូវការការរៀនជាឯកជនដែលពេលខ្លះសឹងតែដូចគ្នានឹងការរៀននៅសាលារដ្ឋដែរ ពីព្រោះការបង្រៀនគឺធ្វើឡើងដោយគ្រូដដែល ហើយពួកគាត់ប្រើប្រាស់កម្មវិធីសិក្សាដូចគ្នានឹងសាលារដ្ឋដែរ។ Brehm and Silova (2014) បានរាយការណ៍ថា ប្រជាជនទូទៅមើលឃើញការបង្រៀនគួរនេះជា ការអប់រំបន្ថែមមួយសម្រាប់បំពេញកម្មវិធីសិក្សានៅតាមសាលារដ្ឋ ដែលពួកគាត់គិតថានៅមានភាពមិនគ្រប់គ្រាន់ពោលគឺ សាលារដ្ឋផ្តល់នូវចំណេះដឹងជាទ្រឹស្តី រីឯការបង្រៀនគួរផ្តល់នូវការអនុវត្តទ្រឹស្តីជាក់ស្តែង។ ដោយផ្អែកលើខ្សែភាពយន្តនិងឯកសារស្តីពីប្រទេសកម្ពុជា ឥណ្ឌា និងទួរគី លោក Kobakhidze (2015) បានសង្កត់ធ្ងន់ពីបែបបទជាសាកលដែលការអប់រំនៅតាមសាលារដ្ឋអាចលាក់បំបាំងការពិត គឺគ្រួសារមានចំណូលទាប បានតស៊ូយ៉ាងលំបាកដើម្បីបង់ថ្លៃការរៀនជាឯកជន។

អ្នកប្រាជ្ញមួយចំនួន បានលើកបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃការបង្រៀនគួរ។ ជាគុណសម្បត្តិ គេយល់ថា ការបង្រៀននេះជួយ ១) សិស្សដែលរៀនយឺតឲ្យរៀនទាន់សិស្សឯទៀត ២) សិស្សដែលពូកែស្រាប់ឲ្យរៀនកាន់តែពូកែថែមទៀត និង ៣) ធ្វើឲ្យសិស្សផ្តោតលើការសិក្សា ជាជាងដើរលេង ប្រើប្រាស់ថ្នាំញៀន ឬឆាប់មានទំនាក់ទំនងផ្លូវភេទជាដើម (Bray and Lykins 2012; Dawson 2011, 2010)។ ជាគុណវិបត្តិ ការបង្រៀនគួរអាចបង្កើតវិសមភាពក្នុងការអប់រំ ពីព្រោះគ្រួសារដែលមានជីវភាពធូរធារ អាចមានលទ្ធភាពបង់ថ្លៃរៀនសូត្រ និងរកបានគ្រូល្អជាងគ្រួសារក្រីក្រ។ ម្យ៉ាងទៀត ការបង្រៀនឯកជនអាចប៉ះពាល់ដល់ការងារ និងគុណភាពបង្រៀនរបស់គ្រូក្នុងសាលាធម្មតា ហើយការរៀនគួរបន្ថែម វាកាត់បន្ថយពេលសម្រាកលំហែ និងពេលវេលានៅជាមួយក្រុមគ្រួសាររបស់សិស្ស (Bray and Lykins 2012: Kobakhidze 2015)។ ម្យ៉ាងវិញទៀត ការបង្រៀនឯកជន ក៏ជាបន្ទុកហិរញ្ញវត្ថុមួយលើគ្រួសារមានចំណូលទាបដែរ (Bray et al. 2016)។

ការប្រៀបធៀបលំនាំនៃការបង្រៀនគួរក្នុងប្រទេសចំនួន ៣០ នៅអាស៊ី បង្ហាញថា ការបង្រៀនឯកជន មានប្រវត្តិយូរលង់ណាស់មកហើយ ហើយវាមានការប្រែប្រួលខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ ទៅតាមកត្តាសេដ្ឋកិច្ច និងវប្បធម៌ខុសៗគ្នា (Bray and Lykins 2012)។ ជាទូទៅ ការបង្រៀនឯកជន អាចរួមចំណែកកែលំអលទ្ធផលសិក្សា ប៉ុន្តែវាក៏អាចប៉ះពាល់ដល់កត្តាសំខាន់ៗផ្សេងទៀត ដូចជា សុខភាពរាងកាយ សីលធម៌ និងភាព

ជាពលរដ្ឋមានទំនួលខុសត្រូវ។ ទោះបីមិនមានភស្តុតាងបង្ហាញច្បាស់ថា ការបង្រៀនឯកជនអាចជួយកែលំអលទ្ធផលសិក្សាក្តី ក៏ឳពុកម្តាយខ្លះជឿថា វាបានជួយពិតមែន (Bray et al. 2016)។ សរុបមក ការបង្រៀនឯកជន និងសកម្មភាពអប់រំបន្ថែម ហាក់ដូចកំពុងរីកដុះដាល ហើយក្លាយជាសកម្មភាពស្របច្បាប់ក្នុងប្រទេសជាច្រើន (Mori and Baker 2010) ។

## *កម្មវិធីសុខភាពរបស់សាលារៀន*

ការសិក្សាមួយចំនួនបានបង្ហាញពីតួនាទីនៃ ការស្រាវជ្រាវពីសុខភាពក្នុងផ្នែកនានានៃវិស័យអប់រំ រួមមាន សុខមាលភាពផ្លូវកាយនិងផ្លូវចិត្ត បំណិនជីវិត និងសុខភាពផ្លូវភេទ។ ការស្រាវជ្រាវពីឥទ្ធិពលនៃការប៉ះពាល់ជាតិពុលអាសេនិក ក្នុងចំណោមសិស្សវិទ្យាល័យនៅខេត្តកណ្តាល បានបញ្ជាក់ថា ជាតិពុលនេះអាចប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ (arsenic neurotoxicity) (Vibol, Hashim and Sarmani 2015)។ ការសិក្សាស្រដៀងគ្នាមួយទៀតបញ្ជាក់ថា ការផ្គត់ផ្គង់ទឹកស្អាតនៅតាមសាលារៀនបានកាត់បន្ថយអត្រាអវត្តមាន និងអត្រាបោះបង់ការសិក្សា (Hunter et al. 2014)។

ការស្រាវជ្រាវពី សុខភាពផ្លូវភេទរបស់សិស្សថ្នាក់មធ្យមសិក្សា កម្រមានណាស់។ Yi et al. (2010) បានសិក្សាពីតួនាទីនៃកត្តាហានិភ័យ និងកត្តាការពារនៅក្នុងទម្លាប់រួមភេទដោយប្រថុយប្រថានរបស់សិស្សមធ្យមសិក្សា អាយុពី ១៤ ទៅ ២០ឆ្នាំ។ ក្នុងចំណោមសិស្ស ១០៤៩នាក់ មាន ១២% រាយការណ៍ថា ខ្លួនមានទំនាក់ទំនងផ្លូវភេទក្នុងអំឡុងពេល ៣ខែកន្លងមក ហើយក្នុងនោះ ៣០% មានដៃគូច្រើនជាងម្នាក់ និង ៥០% មិនបានប្រើស្រោមអនាម័យ។ ដោយផ្អែកលើចម្លើយរបស់សិស្សប្រុសដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ កត្តានាំឲ្យមានទម្លាប់រួមភេទដោយប្រថុយប្រថាននេះ តែងជាប់ទាក់ទងនឹងកត្តាគ្រួសារមានប្រាក់ចំណូលខ្ពស់ សម្ពាធពីមិត្តភក្តិ ការប្រើប្រាស់គ្រឿងញៀន ការធ្លាប់ឃើញអំពើហិង្សាក្នុងសហគមន៍ និងការទទួលបានការគាំទ្រកម្រិតទាបពីក្រុមគ្រួសារ ។

លទ្ធផលស្រាវជ្រាវ បានបង្ហាញជាថ្មីពីភាពបន្ទាន់នៃការអប់រំផ្លូវភេទដែលកំពុងឈានទៅដល់ ការរៀនតាមប្រព័ន្ធអ៊ិនធឺណិត។ គំនិតផ្តួចផ្តើមការរៀនតាមប្រព័ន្ធអ៊ិនធឺណិត (E-learning) សម្រាប់ការអប់រំផ្លូវភេទដល់សិស្សវិទ្យាល័យនេះ ត្រូវបានសាកល្បងក្នុងអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ២៤ ហើយការស្រាវជ្រាវនេះ ក៏ត្រូវបានពង្រីកបន្ថែមទៀតដែរ (Tolson 2014)។ ម្យ៉ាងទៀត ការយល់ដឹងពីទំនោរផ្នែកផ្លូវភេទ និងផលប៉ះពាល់នៃការរើសអើងក្នុងសាលារៀនទៅលើ សិស្សដែលគេស្គាល់ថាជាអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ ឬអ្នកកែភេទ (lesbian, gay, bisexual or transgender: LGBT) នៅមានកង្វះខាតជាខ្លាំង ដូចមានបង្ហាញក្នុងការសិក្សាថ្មីមួយស្តីពីការសំឡុតជាញឹកញយទៅលើយុវជន LGBT ក្នុងសាលារៀននៅកម្ពុជា (CCHR 2015)។

បញ្ហាផ្លូវចិត្ត និងផ្លូវអារម្មណ៍ក្នុងចំណោមយុវជនវ័យក្មេង ជាក្តីបារម្ភដ៏ធំមួយ។ គម្រោងស្រាវជ្រាវពីសុខភាពផ្លូវចិត្តមួយចំនួនដែលបានលើកមកសិក្សាក្នុងអត្ថបទនេះ បានផ្តោតលើកត្តាហានិភ័យនៃការធ្វើអត្តឃាត និងការរាលដាលនៃអត្តឃាតកម្ម។ ការសិក្សាមួយដែលពិនិត្យពីទំនាក់ទំនងរវាង ការផុសគំនិត និងទម្លាប់ធ្វើអត្តឃាតក្នុងស្រទាប់យុវជន ជាមួយនឹង អាកប្បកិរិយាសង្គម ប្រព័ន្ធផ្សព្វផ្សាយ និងសាសនា បានកត់សំគាល់ពីបែបបទដែលប្រព័ន្ធផ្សព្វផ្សាយនិងការបង្រៀនតាមផ្លូវសាសនា បានផ្តល់ព័ត៌មានមិនច្បាស់លាស់ និងមិនជាក់លាក់អំពីភាពតានតឹងចិត្តនឹងសង្គម (Psychosocial stress) និងការគិតចង់សម្លាប់ខ្លួន (Jegannathan, Kullgren and Dahlblom 2015)។ ជាដំណោះស្រាយ ការសិក្សានេះ បានផ្តល់យោបល់ឲ្យបង្កើត កម្មវិធីទប់ស្កាត់ការធ្វើអត្តឃាតនៅតាមសាលារៀន និង កម្មវិធីបណ្តុះបណ្តាលអ្នកប្រឹក្សាយោបល់នៅតាមសាលារៀន ដើម្បីបង្កើនចំណេះដឹងឲ្យកាន់តែធំទូលាយពីបញ្ហាសង្គម អត្តសញ្ញាណផ្នែកយេនឌ័រ សាសនា ក៏ដូចជាបញ្ហាក្នុងគ្រួសារ ដែលអាចជះឥទ្ធិពលមិនល្អទៅលើការសិក្សា និងការអភិវឌ្ឍខ្លួនរបស់សិស្ស។ ការសិក្សាស្រដៀងគ្នាមួយទៀត បានពិនិត្យពីការគិតចង់សម្លាប់ខ្លួនរបស់សិស្សចំនួន ៣២០នាក់ រៀននៅថ្នាក់ទី១០ និង១១ ក្នុងវិទ្យាល័យពីរនៅក្រុងតាខ្មៅ ហើយបានរកឃើញថា សិស្សប្រុសធ្លាប់មានគម្រោងសម្លាប់ខ្លួនញឹកញាប់ជាងសិស្សស្រី ប៉ុន្តែសិស្សស្រីធ្លាប់បានប៉ុនប៉ងសម្លាប់ខ្លួនញឹកញាប់ជាង សិស្សប្រុស (Jegannathan and Kullgren 2011)។

ការស្រាវជ្រាវអំពីក្មេងជំទង់ធ្លាប់ជួបនឹងអំពើហិង្សា បានរកឃើញថា សិស្ស ជាពិសេស សិស្សស្រីដែលធ្លាប់ជួបនឹងអំពើហិង្សាក្នុងគ្រួសារនិងសហគមន៍ តែងមានរោគសញ្ញាបាក់ទឹកចិត្តខ្លាំងច្រើនជាងគេ (Yi et al. 2013)។ ដូចនេះ យុទ្ធសាស្ត្រសម្រាប់បង្កើតសហគមន៍មានសុវត្ថិភាព និងគ្មានអំពើហិង្សា និងសម្រាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ អាចជួយកាត់បន្ថយបានច្រើននូវការបាក់ទឹកចិត្តក្នុងចំណោមយុវជន (Yi et al. 2013)។ ជាក់ស្តែង កម្មវិធីបំណិនជីវិតនៅវិទ្យាល័យពីរក្នុងក្រុងតាខ្មៅ បានជួយកែលំអសុខមាលភាពផ្លូវចិត្តរបស់សិស្ស ហើយបានកាត់បន្ថយទម្លាប់ប្រថុយគ្រោះថ្នាក់របស់ ក្មេងប្រុសជំទង់ (Jegannathan, Dahlblom and Kullgren 2014)។

## **ការពិភាក្សា និងទិសដៅស្រាវជ្រាវនៅអនាគត**

អត្ថបទនេះបានគូសបញ្ជាក់ពីគម្លាតដ៏ធំរវាង ការស្រាវជ្រាវគោលនយោបាយផ្នែកអប់រំ ជាមួយនឹង ដំណើរការអប់រំជាក់ស្តែងនៅតាមវិទ្យាល័យ។ពិតហើយមានការស្រាវជ្រាវជាច្រើនដែលត្រូវធ្វើជាបន្ទាន់ ប៉ុន្តែក្នុងនោះ យើងគួរយកចិត្តទុកដាក់ជាពិសេសលើ ៤ចំណុច៖ ១)ការបង្កើនគុណភាព ២) កម្មវិធីសិក្សានិងគរុកោសល្យ ៣) ការបង្រៀនគួរ និង ៤) ការចូលរួមក្នុងសង្គម ការអភិវឌ្ឍផ្លូវចិត្ត និងការសិក្សារបស់សិស្ស។

ការស្រាវជ្រាវ បានបញ្ជាក់បន្តទៀតថា កង្វះការអប់រំមានគុណភាព និងគ្រូបង្រៀនមានការបណ្តុះបណ្តាលត្រឹមត្រូវ (អ្នកពាក់ព័ន្ធសំខាន់ក្នុងការកែលំអការអប់រំ) ជាបញ្ហាប្រឈមធំជាងគេ។ ការវិភាគស៊ីជម្រៅបន្ថែម គួរពិនិត្យលើសំណួរគន្លឹះដូច

*តទៅទំព័រ ១៤*

# អភិបាលកិច្ចទឹកសម្រាប់ភាពធន់នឹងអាកាសធាតុ៖ លទ្ធផលសិក្សាពីថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ


## សាវតា

ឆ្លើយតបនឹងការអំពាវនាវឲ្យមាន ការស្វែងយល់កាន់តែប្រសើរពីវិធីដែលសហគមន៍ត្រូវអនុវត្តដើម្បីបង្កើនសមត្ថភាពបន្សាំ ការដាក់បញ្ចូលចំណេះដឹងនៅតាមមូលដ្ឋាន និងចំណេះដឹងបែបវិទ្យាសាស្ត្រ ទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងអភិបាលកិច្ចបានកែសម្រួលឲ្យបម្រើអាទិភាពនៅតាមមូលដ្ឋាននោះ វិទ្យាស្ថាន CDRI នៅឆ្នាំ២០១៣ បានចាប់អនុវត្តកម្មវិធីស្រាវជ្រាវរយៈពេល ៣ឆ្នាំ ដោយមានការចូលរួមពីមូលដ្ឋាន (Sam and Pech 2015)។ ក្នុងនេះ មានការសិក្សាតូចៗជាប់ទាក់ទងគ្នាមួយស៊េរីដែលអនុវត្តឡើង ដើម្បីពិនិត្យពីអភិបាលកិច្ចទឹក និងភាពធន់ផ្នែកសង្គមនិងអេកូឡូស៊ី នៅក្នុងដែនរងទឹកភ្លៀងដែលងាយរងគ្រោះជាងគេចំនួន ៣ នៅអាងទន្លេសាបគឺ ស្ទឹងជីនិត ស្ទឹងជ្រៃបាក់ និងស្ទឹងពោធិ៍សាត់ (Sam et al. 2015)។

ការគ្រប់គ្រងទឹកនៅកម្ពុជា មានលក្ខណៈគួរកត់សំគាល់មួយគឺប្រភពទឹកសម្បូរណាស់ តែប្រែប្រួលខ្លាំងទៅតាមតំបន់ និងពេលវេលា។ ទឹកច្រើនពេក ឬតិចពេក ជាបញ្ហាទូទៅមួយ ដែលតែងយាយីសហគមន៍ជនបទ និងកសិករ ក្នុងតំបន់ជាច្រើននៅកម្ពុជា ជាពិសេសនៅតំបន់អាងទន្លេសាប។ ការស្វែងរកដំណោះស្រាយជួបការលំបាក ព្រោះមានបញ្ហាផ្នែកអភិបាលកិច្ចចោទច្រើនដែលផុសចេញពី របាយមិនស្មើគ្នានៃទឹកស្រោចស្រពឧបសគ្គផ្សេងៗរារាំងដល់ ការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការគ្រប់គ្រងទឹក តួនាទី និងទំនួលខុសត្រូវជាន់គ្នាក្នុងចំណោមស្ថាប័នរដ្ឋ និងសមត្ថភាពស្ថាប័ននៅទន់ខ្សោយ និងមានធនធានមិនគ្រប់គ្រាន់។ ស្ថានការណ៍កាន់តែស្មុគស្មាញថែមទៀតដោយសារសមត្ថភាពខ្សោយនៃប្រព័ន្ធមនុស្ស និងធម្មជាតិ ក្នុងការបន្សាំឲ្យបានលឿនទាន់ពេលទៅនឹង ការប្រែប្រួលអាកាសធាតុ។ ដូច្នេះជាការសំខាន់ណាស់ ដែលត្រូវមានអភិបាលកិច្ចនៅថ្នាក់មូលដ្ឋានដ៏រឹងមាំ គួរឲ្យទុកចិត្ត និងពោរពេញដោយថាមពល។

អត្ថបទនេះ សង្ខេបលទ្ធផលចម្បងៗនៃការវាយតម្លៃពីអភិបាលកិច្ចទឹកនៅក្នុងដែនរងទឹកភ្លៀងទាំង៣ ដែលបានសិក្សាក្នុងបរិបទអាចមានការប្រែប្រួលអាកាសធាតុ ដូចបានប្រមើលឃើញនៅថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ (Sam et al. 2015)។ ជាសេចក្តីសន្និដ្ឋាន អត្ថបទនេះមានផ្តល់ជាមតិយោបល់មួយចំនួនសម្រាប់ពង្រឹងអភិបាលកិច្ចទឹក ដែលអាចជួយសម្រេចឲ្យបាននូវសន្តិសុខទឹក និងកសាងភាពធន់នឹងអាកាសធាតុ។


## ការជ្រើសរើសទីតាំងសិក្សា និងការប្រមូលទិន្នន័យ

ការសិក្សានេះ អនុវត្តក្នុងឆ្នាំ២០១៥ ក្នុងដែនរងទឹកភ្លៀងចំនួន ៣ (ពោធិ៍សាត់ ជីនិត និងជ្រៃបាក់) នៅក្នុងអាងទន្លេសាប។ ដែនរងទឹកភ្លៀងទាំងនេះ ត្រូវបានជ្រើសយក ពីព្រោះវាងាយរងគ្រោះជាពិសេសទៅនឹងហានិភ័យជាប់ទាក់ទងនឹងអាកាសធាតុ ដែលបង្កឡើងដោយ ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ។ ទិន្នន័យបឋម ប្រមូលបានពី ៦សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) (២សហគមន៍ក្នុងដែនរងទឹកភ្លៀងនីមួយៗ) ដែលត្រូវបានជ្រើសរើស ដោយសារសហគមន៍ទាំងនោះ តែងតែជួបប្រទះបញ្ហាកង្វះទឹក ទឹកជំនន់តាមរដូវកាល និងជម្លោះទឹក។ សម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ បានអនុវត្តជាមួយសមាជិក និងប្រធានសកបទ នីមួយៗ។ ទិន្នន័យប្រភពទី២ ទទួលបានពីឯកសារគោលនយោបាយ របាយការណ៍ផ្សេងៗ និងឯកសារបោះពុម្ពផ្សាយមានស្រាប់។

លទ្ធផលសិក្សាបឋម បានទទួលការបញ្ជាក់ពីភាពត្រឹមត្រូវនៅក្នុងសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ខេត្ត ដែលមានការចូលរួមពីប្រជាជនមូលដ្ឋាន អាជ្ញាធរមូលដ្ឋាន សមាជិក សកបទ ព្រមទាំងទីភ្នាក់ងារ និងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ខេត្ត។

## លទ្ធផលសិក្សាសំខាន់ៗ

ការស្រាវជ្រាវនេះ អនុវត្តតាម ក្របខ័ណ្ឌបានប្រើប្រាស់ក្នុងគម្រោងអភិបាលកិច្ចប្រព័ន្ធផែនដី សម្រាប់វិភាគពីភាពធន់នៃប្រព័ន្ធអេកូឡូស៊ីនិងសង្គម ដែលមានរៀបចំកិច្ចសន្ទនាជុំវិញប្រធានបទ ៥៖ របៀបរៀបចំ គណនេយ្យភាព ការលៃចែក/លទ្ធភាពប្រើប្រាស់ លទ្ធភាពបន្សាំ និង ទីភ្នាក់ងារ (Biermann et al. 2010)។ លទ្ធផលសិក្សានេះ ក៏មានបែងចែកជាក្រុមៗ តាមប្រធានបទទាំងនោះដែរ។

### *របៀបរៀបចំ*

របៀបរៀបចំអភិបាលកិច្ច បានលើកមកសិក្សាស្រាវជ្រាវដោយពិនិត្យជាសំខាន់លើ លក្ខណៈផ្នែកស្ថាប័ន ដែលមានជាអាទិ៍ សំណុំបទបញ្ញត្តិ និងនីតិវិធី មានចែងក្នុងច្បាប់ និងគោលនយោបាយ ឬបទដ្ឋានសង្គម ដោយផ្តោតលើរបៀបរបបសម្រាប់តួអង្គរដ្ឋ និងមិនមែនរដ្ឋ និងអង្គការក្រៅផ្លូវការ។ នៅថ្នាក់ក្រោមជាតិ ស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចច្រើនជាងគេផ្នែកអភិបាលកិច្ចទឹក គឺ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត (PDOWRAM) មន្ទីរកសិកម្មខេត្ត (PDA) និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM)។ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ មន្ទីរបរិស្ថានខេត្ត (PDE) ក៏ដើរតួនាទីសំខាន់ណាស់ដែរ។ មន្ទីរខេត្តទាំងនេះ ស្ថិតក្រោមឱវាទរបស់ក្រសួង និងគណៈកម្មាធិការថ្នាក់ជាតិរៀងៗខ្លួន។

---

អត្ថបទនេះ រៀបរៀងដោយលោកស្រី សំ ស្រីមុំ ប្រធានស្តីទី ផ្នែកបរិស្ថាន នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Sam Sreymom. 2016. “Water Governance for Climate Resilience: Findings from Subnational and Local Levels.” Cambodia Development Review 20(2):6-9.

នៅថ្នាក់មូលដ្ឋាន ការបង្កើត សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) បានដើរទន្ទឹមគ្នានឹងកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ (D&D) ដែលសំដៅជំរុញ ការគ្រប់គ្រងក្នុងមូលដ្ឋានប្រកបដោយចីរភាពនូវ ទឹកស្រោចស្រពសម្រាប់ម្ចាស់ដីតូចៗ។ សកបទ មានសិទ្ធិអំណាចបែងចែកទំនួលខុសត្រូវលើការគ្រប់គ្រងទឹកស្រោចស្រព ជាមួយគ្នានឹង មន្ទីរធនធានទឹកខេត្ត ហើយស្ថាប័នទាំងពីរ ត្រូវសហការគ្នាក្នុងការថែទាំ និងដំណើរការគម្រោងស្រោចស្រព។ សកបទ ត្រូវរាយការណ៍ពីសកម្មភាព និងដំណើរការលូតលាស់ការងាររបស់ខ្លួន ទៅឲ្យ មន្ទីរធនធានទឹកខេត្ត ដែលក្នុងឋានៈជាអ្នកគ្រប់គ្រងកំពូល ត្រូវផ្តល់ជំនួយគាំទ្រផ្នែកបច្ចេកទេស។ ចំណុចសំខាន់មួយទៀតគឺ មានការអញ្ជើញប្រជាជនមូលដ្ឋាន ឲ្យចូលរួមក្នុងការសម្រេចចិត្តស្តីពីការគ្រប់គ្រងទឹក។ អាជ្ញាធរឃុំ ក៏ចូលរួមក្នុងអភិបាលកិច្ចទឹកនៅថ្នាក់មូលដ្ឋានដែរ ដោយមានសមាជិកក្រុមប្រឹក្សាឃុំម្នាក់ ឬច្រើននាក់ ស្ថិតក្នុងគណៈកម្មាធិការ សកបទ ឬចូលរួមដោះស្រាយបញ្ហាផ្សេងៗទាក់ទងនឹងទឹក។ សហគមន៍កសិករប្រើប្រាស់ទឹក ត្រូវរាយការណ៍ពីដំណើរការលូតលាស់ការងារ និងសកម្មភាពរបស់ខ្លួន ទៅឲ្យមេឃុំរៀងៗខ្លួន។

ក្នុងចំណោមវិស័យជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងទឹក ភារកិច្ចរបស់ មន្ទីរកសិកម្មខេត្ត ក្នុងការបង្កើនផលិតកម្មកសិកម្មមានការស្រោចស្រព ត្រូវផ្សារភ្ជាប់ដាច់ខាតទៅនឹងបញ្ហាសន្តិសុខទឹក។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ដែលទទួលខុសត្រូវលើការផ្តល់ជំនួយសង្គ្រោះនៅពេលមានគ្រោះមហន្តរាយ និងផ្តល់ជំនួយគាំទ្រផ្នែកបច្ចេកទេស ក្នុងការធ្វើផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយនៅថ្នាក់ឃុំនោះ តែងចូលរួមជាសំខាន់ក្នុងការគ្រប់គ្រងមហន្តរាយទាក់ទងនឹងទឹក និងហានិភ័យមានទឹកជំនន់ និងគ្រោះរាំងស្ងួត។ មន្ទីរបរិស្ថានខេត្ត ជាអ្នកពាក់ព័ន្ធមួយដែរ ព្រោះមានសមត្ថកិច្ចគ្រប់គ្រងហានិភ័យមានផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ មន្ទីរបរិស្ថានខេត្ត អនុវត្តសកម្មភាពបន្សាំ និងសម្រាលផលប៉ះពាល់នៅក្នុងមូលដ្ឋាន។ គម្រោងផ្សេងៗដែលផ្តោតលើ ការគ្រប់គ្រងទឹកនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ បានជំរុញឲ្យមានកិច្ចប្រឹងប្រែងដោយមានការសម្របសម្រួលគ្នា និងពង្រឹងតំណភ្ជាប់រវាងស្ថាប័នទាំងនេះ។ ទោះយ៉ាងនេះក្តី សមត្ថភាពស្ថាប័ននិងបច្ចេកទេសមានកម្រិត និងកង្វះលទ្ធភាពឆ្លើយតបឲ្យបានលឿនគ្រប់គ្រាន់ទៅនឹងតម្រូវការនិងបញ្ហាចោទនៅតាមមូលដ្ឋាន គឺជាបញ្ហាប្រឈមដ៏ចម្បងក្នុងការគ្រប់គ្រងធនធានទឹក។

ការវិភាគពីកំណែទម្រង់ D&D ដែលក្នុងនោះ អាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវបង្កើតផែនការអភិវឌ្ឍរៀងៗខ្លួន សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការថ្នាក់ជាតិ បានបង្ហាញថា D&D មានដំណើរការយឺតជាងការរំពឹងទុក (MOE 2012)។ ដំណើរការបែបផ្លូវការពេកនេះ រាំងស្ទះដល់ការដាក់បញ្ចូលគំនិតផ្សេងៗលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹក (MOE 2012)។ ក្នុងពេលដំណាលគ្នានេះ កង្វះឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ ភាពដាច់ដោយដុំផ្នែកស្ថាប័ន និងកង្វះធនធានមនុស្ស បានរាំងស្ទះដល់ការបន្សុីគ្នារវាងក្របខ័ណ្ឌស្ថាប័ន ជាមួយនឹងការបង្កើនសមត្ថភាពដើម្បីកសាងភាពធន់។ ម្យ៉ាងទៀត វិនិយោគ ការកសាងភាពធន់ និងគំនិតផ្តួចផ្តើមលើកកម្ពស់ការយល់ដឹង តែងប្រមូលផ្តុំនៅថ្នាក់ជាតិ ដែលនាំឲ្យមានកង្វះសមត្ថភាពច្រើន នៅថ្នាក់ក្រោមជាតិ ក្នុងនោះមានទាំងសមត្ថភាព និងការយល់ដឹងពីស្ថាប័នផង។

## *គណនេយ្យភាព*

គណនេយ្យភាព សំដៅលើ "ទំនួលខុសត្រូវនៃភាគីមួយក្នុងការប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ទៅលើភាគីម្ខាងទៀត" (Chheat et al. 2011, 13)។ នាបច្ចុប្បន្ន យន្តការគណនេយ្យភាពសាធារណៈនៅទន់ខ្សោយនៅឡើយ ក្នុងរដ្ឋអំណាចថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ទំនាក់ទំនងពីលើចុះក្រោម នៅមានច្រើនលើសលុប ហើយវារារាំងដល់លទ្ធភាពបានប្រើប្រាស់ព័ត៌មានគួរឲ្យជឿជាក់ និងស្ថាប័នផ្លូវការ។ ដូច្នេះ ត្រូវមានការយកចិត្តទុកដាក់កាន់តខ្លាំងទៅលើ ការកែលំអទំនាក់ទំនង និងអន្តរកម្មតាមខ្សែផ្តេក (UNDP 2013)។ នៅថ្នាក់ក្រោមជាតិ ទោះបីមានកំហិតជាច្រើនក្តី ក៏ការចូលរួម និងគណនេយ្យភាព អាចមើលឃើញច្បាស់តាមរយៈបែបបទដែលអាជ្ញាធរមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការក្នុងមូលដ្ឋាន និងជំរុញឲ្យប្រជាជនមូលដ្ឋាន ចូលរួមក្នុងដំណើរការធ្វើផែនការវិនិយោគ និងអភិវឌ្ឍន៍ឃុំ។

ក្នុងការប្រជុំកំណត់អាទិភាពក្នុងភូមិ មានការសាកសួរប្រជាជនមូលដ្ឋានពីគំនិតរបស់គាត់លើ អាទិភាពនៃការអភិវឌ្ឍក្នុងមូលដ្ឋានដែលជាប់ទាក់ទងសឹងតែរាល់លើកទៅនឹង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ប្រឡាយស្រោចស្រព និងសំណង់គ្រប់គ្រងទឹកជំនន់ ជាដើម។ គម្រោងទាំងនេះត្រូវបានកំណត់អាទិភាព និងចុះក្នុង ផែនការអភិវឌ្ឍន៍ឃុំ ប៉ុន្តែសេចក្តីសម្រេចផ្តល់មូលនិធិឲ្យគម្រោងណាមួយ ត្រូវធ្វើឡើងនៅក្នុង សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកប្រចាំឆ្នាំ ដែលនៅពេលនោះ ផែនការអភិវឌ្ឍន៍ឃុំ ត្រូវយកទៅបូកបញ្ចូលជាមួយផែនការរបស់មន្ទីរជំនាញនានា។ បន្ទាប់មក NGOs ណាដែលមានចំណាប់អារម្មណ៍ គឺអាចជ្រើសយកគម្រោងខ្លះដើម្បីផ្តល់ជំនួយទ្រទ្រង់។ ដោយសារកង្វះហិរញ្ញវត្ថុ សំណើពីថ្នាក់មូលដ្ឋាន មិនអាចបំពេញបានទាំងអស់ទេ។ តម្រូវការរបស់ សកបទ ក៏ទទួលបានចម្លើយតបមានកំហិតដូចគ្នា ប៉ុន្តែការជួបប្រជុំជាទៀងទាត់ បានញ៉ាំងឲ្យមានទំនាក់ទំនងចុះឡើងប្រកបដោយប្រសិទ្ធភាព រវាងគណៈកម្មការគ្រប់គ្រង ជាមួយនឹង សមាជិក សកបទ ។

កង្វះភាពសម្រាប់គ្រប់គ្នា និងលំហូរព័ត៌មានយឺត បានរាំងស្ទះដល់តម្លាភាព។ បញ្ហានេះជះឥទ្ធិពលភាគច្រើនទៅលើតួអង្គថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ ធ្វើឲ្យពួកគេចូលរួមបានតិចនៅក្នុងអភិបាលកិច្ចទឹក ការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ព័ត៌មានស្តីពីអាកាសធាតុ និងទឹកជាពិសេសអំពីចម្លើយតបផ្នែកបន្សាំ បរិមាណទឹកដែលមានសម្រាប់ដែនរងទឹកភ្លៀងនីមួយៗ និងការប្រើម៉ូដែលប៉ាន់ស្មានពីចំនួនទឹកនៅសល់ឬខ្វះ ខាងអាជ្ញាធរថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ នៅមិនទាន់មាន ឬមិនទាន់ចេះប្រើទេ។

### *ការបែងចែក និងលទ្ធភាពប្រើប្រាស់*

ការបែងចែក និងលទ្ធភាពប្រើប្រាស់ធនធានសំខាន់ៗ (រូបវន្ត ធម្មជាតិ សង្គម មនុស្ស និងហិរញ្ញវត្ថុ) ដើម្បីលើកកម្ពស់ការគ្រប់គ្រងទឹក និងទប់ទល់នឹងការប្រែប្រួលអាកាសធាតុ វាមានលក្ខណៈមិនស្មើគ្នា ដែលធ្វើឲ្យយឺតយ៉ាវ ឬគាំងដល់ការសាកល្បង និងគំនិតបែបថ្មី សម្រាប់ការកសាងសមត្ថភាពបន្សាំ និងភាពធន់។ ឧទាហរណ៍ គម្រោងស្រោចស្រពដែលអាចជួយកាត់បន្ថយឥទ្ធិពលទឹកជំនន់ និងគ្រោះរាំងស្ងួត មិនទាន់ដំណើរការបានពេញកម្លាំងទេ ព្រោះមានការរចនារៀបចំមិនសូវល្អ ដែនគ្រប ដណ្តប់តូច និងផ្តល់ទឹកស្រោចស្រពមិនបានស្មើភាពគ្នា។ ធនធានធម្មជាតិ រួមទាំងទឹក និងធាតុចូលកសិកម្ម នៅមានកំហិតខ្លាំង និងផ្តល់លទ្ធភាពឲ្យប្រើប្រាស់មិនបានស្មើគ្នា។ ជាចំណុចវិជ្ជមាន ក្រុមសន្សំប្រាក់នៅមូលដ្ឋាន និងបណ្តាញមូលដ្ឋាន បានជួយប្រជាជនក្នុងការទប់ទល់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងកសាងផែនការស្តារជីវភាពខ្លួនឡើងវិញ។ ទោះបីមានវិសាលភាពតូចក៏ដោយ ក៏ស្ថាប័នផ្លូវការ និងក្រៅផ្លូវការបែបនេះនៅតាមមូលដ្ឋាន អាចរួមចំណែកបានច្រើនក្នុងកិច្ចប្រឹងប្រែងដើម្បីបន្សាំខ្លួន។ ធនធានមនុស្ស និងហិរញ្ញវត្ថុ ក៏មានកំហិតដែរ ប៉ុន្តែកំពុងរីកលូតលាស់ ដោយសារកំណើនចំណាប់អារម្មណ៍លើបញ្ហាប្រែប្រួលអាកាសធាតុ។

### *លទ្ធភាពបន្សាំ*

ការវិភាគពីលទ្ធភាពបន្សាំនៃអភិបាលកិច្ចទឹក ប្រមូលផ្តុំលើភាពបត់បែននៃក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពស្ថាប័នក្នុងការរៀនសូត្រ។ ទាំងទីភ្នាក់ងារ និងរបៀបរៀបចំ មានលក្ខណៈរឹងកំព្រឹសនៅចំពោះមុខការប្រែប្រួលអាកាសធាតុភ្លាមៗ។ វិធីសាស្ត្រពីលើចុះក្រោម និងកង្វះធនធានសំខាន់ៗ ជាមូលហេតុចម្បងនៃភាពមិនអាចបត់បែនបានរបស់ស្ថាប័ន។ ក្នុងនេះ ការឃ្លាំមើល និងវាយតម្លៃ អាចជាឧទាហរណ៍ដ៏ល្អបំផុតមួយ។ ដោយសារឧបសគ្គផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុនោះ ការឃ្លាំមើល និងវាយតម្លៃមានអនុវត្តតែនៅថ្នាក់ជាតិប៉ុណ្ណោះ ថ្វីបើមានចុះនៅក្នុងផែនការគ្រប់គ្រងគ្រោះមហន្តរាយរបស់ឃុំក្តី ហើយបញ្ហានេះនាំឲ្យកិច្ចប្រឹងប្រែងរៀបចំស្ថាប័នដើម្បីជំរុញភាពធន់ និងការបន្សាំទូទាំងប្រទេស ត្រូវរឹងគាំងមិនអាចបត់បែនបាន។

លទ្ធភាពរៀនសូត្រ ប្រែប្រួលខុសគ្នាខ្លាំងក្នុងចំណោមអង្គការផ្សេងៗ៖ អង្គការណាបានចូលរួមកាន់តែច្រើនក្នុងការងារសម្រាលឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ អង្គការនោះក៏កាន់តែយល់ដឹងច្រើនពីបញ្ហាចោទក្នុងការបន្សាំ និងការអភិវឌ្ឍជំនាញដើម្បីទប់ទល់នឹងឥទ្ធិពលទាំងនោះ។ រដ្ឋអំណាចថ្នាក់ក្រោមជាតិ ក៏ដូចជាអង្គការសង្គមស៊ីវិល បានយល់ដឹងច្រើនណាស់ពី ការប្រែប្រួលអាកាសធាតុ រីឯអាជ្ញាធរមូលដ្ឋាន ក៏បានរៀនសូត្រពីគ្រោះមហន្តរាយ និងស្ថានភាពនានា ដែលពួកគេត្រូវជួបប្រទះដែរ។ កិច្ចប្រឹងប្រែងពង្រឹងអភិបាលកិច្ចប្រព័ន្ធសង្គម-អេកូឡូស៊ី ដែលមានលក្ខណៈបត់បែនល្អ ទាមទារឲ្យមានកត្តាជាច្រើន ជាពិសេសព័ត៌មានងាយរកបានស្តីពីអាកាសធាតុ និងធាតុអាកាស ហើយនិងធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់។

### *ទីភ្នាក់ងារ*

ទីភ្នាក់ងារក្នុងការសិក្សានេះ សំដៅដល់ស្ថាប័នមិនមែនរដ្ឋដែលធ្វើការក្នុងផ្នែកអភិបាលកិច្ច និងការប្រែប្រួលអាកាសធាតុ។ តួអង្គមិនមែនរដ្ឋ មានជាអាទិ៍ សង្គមស៊ីវិល វិស័យឯកជន មជ្ឈដ្ឋានសិក្សាអប់រំ មជ្ឈមណ្ឌលស្រាវជ្រាវ និងសមាគមផ្លូវការនិងក្រៅផ្លូវការ។ តួអង្គទាំងនេះ មានប្រសិទ្ធភាពក្នុងការពង្រឹងភាពធន់នៅមូលដ្ឋាន តាមរយៈជំនួយទ្រទ្រង់ ដូចជា សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការលើកកម្ពស់ការយល់ដឹងពីយុទ្ធសាស្ត្រ និងវិធីសាស្ត្របន្សាំនឹងអាកាសធាតុ ជាពិសេសសម្រាប់វិស័យទឹក និងកសិកម្ម ការស្តារឡើងវិញ និងការកសាងសំណង់ស្រោចស្រព និងផ្គត់ផ្គង់ទឹកខ្នាតតូច ពិពិធកម្មរបៀបចិញ្ចឹមជីវិត និងការបង្កើតអង្គការក្រៅផ្លូវការនៅមូលដ្ឋាន ដូចជា ក្រុមសន្សំប្រាក់ ធនាគារស្រូវ និងក្រុមផលិតករបន្លែនិងសត្វចិញ្ចឹម។ ក្រុមទាំងនេះ ដើរតួនាទីសំខាន់ណាស់ក្នុងការជួយប្រជាជនទប់ទល់ និងងើបឡើងវិញពីគ្រោះមហន្តរាយនានា។ តួអង្គមនុស្សធម៌ដទៃទៀត ដូចជាក្រុមសាសនាជាដើម ដើរតួនាទីដ៏សំខាន់ក្នុងការជួយសហគមន៍មូលដ្ឋានទប់ទល់នឹងសម្ពាធ និងវិសមរូបអាកាសធាតុ តាមរយៈការរៀបចំឲ្យមានកិច្ចប្រឹងប្រែងសង្គ្រោះបន្ទាន់ នៅពេលមានគ្រោះមហន្តរាយ និងការផ្តល់អំណោយជាប្រាក់ និងគ្រឿងផ្គត់ផ្គង់នានា។ ការចូលរួមរបស់វិស័យឯកជនក្នុងការគ្រប់គ្រងទឹក ក៏កាន់តែសំខាន់ឡើងដែរ សម្រាប់ការធ្វើកសិកម្មដោយប្រើប្រព័ន្ធស្រោចស្រព។

សង្គមស៊ីវិលដើរតួនាទីសំខាន់ណាស់ ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹក ដោយមានអង្គការជាច្រើនកំពុងជួយទ្រទ្រង់ផ្តល់គំនិតបែបថ្មីនៅមូលដ្ឋាន។ ប៉ុន្តែការរួមចំណែករបស់សង្គមស៊ីវិល ក្នុងការជំរុញភាពធន់រយៈពេលវែង ត្រូវជួបបញ្ហាប្រឈមជាច្រើន ក្នុងនោះ បញ្ហាចម្បងគេអាចជា ការឈានទៅទ្រទ្រង់ខ្លួនឯងឲ្យមានចីរភាព នៅពេលចប់ជំនួយ។ ពិតហើយ របៀបវារៈ និងវដ្តខ្លីៗនៃការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ អាចរាំងដល់ចម្លើយតបផ្សេងៗផ្នែកបន្សាំដែលមានប្រសិទ្ធភាព និងអាចពង្រីកដោយខ្លួនឯងបាន។ បញ្ហាប្រឈមផ្នែកចីរភាព កាន់តែធ្ងន់ធ្ងរឡើង ដោយសារតែអន្តរាគមន៍ទប់ទល់នឹងការប្រែប្រួលអាកាសធាតុ មិនមានការសម្របសម្រួលល្អ និងមានលក្ខណៈរដិបរដុប (UNDP 2013)។ កត្តាអាចជួយឲ្យអាជ្ញាធរមូលដ្ឋាន NGOs និងសហគមន៍ សហការគ្នាល្អ និងរក្សាបាននូវសមត្ថភាពបន្សាំ និងកិច្ចប្រឹងប្រែងពង្រឹងភាពធន់ រួមមាន បណ្តាញមូលដ្ឋាន របៀបរៀបចំស្ថាប័នផ្លូវការ និងមិនផ្លូវការ ការផ្តល់សិទ្ធិអំណាចឲ្យសហគមន៍ និងផែនការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែលគិតគូរដល់ការពិតជាក់ស្តែងទាំងឡាយ (ឧទាហរណ៍ ឧបសគ្គផ្នែកស្ថាប័ន ហិរញ្ញវត្ថុ និងសមត្ថភាព)។

អភិបាលកិច្ចទឹក និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ទាមទារឲ្យមានកិច្ចសហការជិតស្និទ្ធ និងរឹងមាំរវាងរដ្ឋអំណាចថ្នាក់ជាតិ នឹងថ្នាក់ក្រោមជាតិ។ ប៉ុន្តែទោះបីជាវិធីសាស្ត្ររបស់ពួកគេមានលក្ខណៈស្របគ្នាក៏ដោយ ក៏កម្មវិធីរបស់ពួកគេមិនបានផ្តុំកម្លាំងគ្នា ដល់កម្រិតមួយដែលធ្វើឲ្យវិធានការអនុវត្តគោល

នយោបាយនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន អាចអនុវត្តទៅបានយ៉ាងរលូននោះទេ។ មូលហេតុមួយនៃបញ្ហាប្រឈមក្នុងការរួមបញ្ចូលគ្នានេះ គឺការអនុវត្ត D&D យឺតជាងផែនការ៖ ភាពរារែកក្នុងការផ្ទេរថវិកា និងសិទ្ធិអំណាចទៅឲ្យថ្នាក់ក្រោមជាតិ ដែលធ្វើឲ្យសិទ្ធិអំណាចក្នុងការសម្រេចចិត្តប្រមូលផ្តុំតែនៅថ្នាក់ជាតិ។

## វិធីលើកកម្ពស់អភិបាលកិច្ចទឹក ដើម្បីសន្តិសុខទឹក និងភាពធន់នឹងអាកាសធាតុ៖ មធ្យោបាយឆ្ពោះទៅមុខ

ការវាយតម្លៃនេះ ពិនិត្យពីអភិបាលកិច្ចទឹក តាមរយៈក្របខ័ណ្ឌគ្រប់គ្រងមានភាពបត់បែន ៥ជំហាន៖ របៀបរៀបចំស្ថាប័នគណនេយ្យភាពនិងតម្លាភាព ការលែចែកនិងលទ្ធភាពប្រើប្រាស់ធនធានសំខាន់ៗ លទ្ធភាពបន្សាំ និងទីភ្នាក់ងារក្រៅពីស្ថាប័នរដ្ឋ។ ជំហាននីមួយៗ មានបញ្ហាប្រឈម និងឱកាសល្អរៀងៗខ្លួន ប៉ុន្តែមានការជាប់ពាក់ព័ន្ធគ្នា។ មានចំណុចជាច្រើនអាចកែលំអឡើងទៀត ដើម្បីជួយទ្រទ្រង់ដល់អភិបាលកិច្ចទឹក និងការបន្សាំកាន់តែប្រសើរទៅនឹងការប្រែប្រួលអាកាសធាតុ។ ទោះបីមានឧបសគ្គផ្នែកស្ថាប័ន បច្ចេកទេស និងហិរញ្ញវត្ថុក៏ដោយ ក៏ឱកាសល្អ និងដំណោះស្រាយក្នុងការគ្រប់គ្រង ដើម្បីលើកកម្ពស់សន្តិសុខទឹក និងភាពបន្សាំនឹងអាកាសធាតុ បានទាក់ទាញជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសយ៉ាងច្រើនពីជុំវិញពិភពលោក។ ខាងក្រោមនេះ ជាមតិយោបល់មួយចំនួនស្តីពីវិធានការដែលអាចជួយពង្រឹងរបៀបរៀបចំការគ្រប់គ្រងទឹកនៅកម្ពុជា ដើម្បីសម្រេចបាននូវអភិបាលកិច្ចទឹកមានភាពបន្សាំល្អ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

- តម្រង់ទិសការកសាងសមត្ថភាព និងការពង្រឹងស្ថាប័ន ឲ្យវាឆ្លុះបញ្ចាំងពីអាទិភាពរបស់រដ្ឋអំណាចថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន ដោយមានការគិតគូរពី ចំណេះដឹងនិងជំនាញក្នុងមូលដ្ឋាន និងការដាក់បញ្ចូលនូវប្រជាជនដែលមានស្ថានភាពខុសៗគ្នា។
- ទទួលស្គាល់ពីតួនាទីរបស់ NGOs ស្ថាប័នក្រៅផ្លូវការ ក្រុមនិងបណ្តាញផ្សេងៗក្នុងមូលដ្ឋាន (ឧទាហរណ៍ ទីភ្នាក់ងារក្រៅពីស្ថាប័នរដ្ឋ) ក្នុងការសម្រាលផលប៉ះពាល់ពីអាកាសធាតុ ដើម្បីកែលំអប្រសិទ្ធភាពនៃអន្តរាគមន៍ផ្នែកទឹក និងការបន្សាំតាមផែនការ។
- ពន្លឿនដំណើរការ D&D ជាពិសេស ការផ្ទេរមុខងារ និងធនធាន ដើម្បីជួយទ្រទ្រង់ និងផ្តល់សិទ្ធិអំណាចដល់រដ្ឋអំណាចថ្នាក់ក្រោមជាតិ និង សកបទ។
- ដាក់បញ្ចូលវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយគ្រោះមហន្តរាយ ជាមួយនឹង ការពង្រឹងការគ្រប់គ្រងធនធានទឹក ដើម្បីលើកកម្ពស់សមត្ថភាពបន្សាំ និងកាត់បន្ថយភាពងាយរងគ្រោះ។
- ធ្វើឲ្យរលូនល្អនូវ ការដោះដូរនិងលំហូរព័ត៌មានដោយសេរី និងកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន ដើម្បីលើកកម្ពស់ការរៀនសូត្រមានលក្ខណៈបន្សាំល្អ ដែលអាចជួយផ្តល់ព័ត៌មានដល់ការកសាងគោលនយោបាយ ការធ្វើផែនការ ការកាត់បន្ថយហានិភ័យ និងការរៀបចំខ្លួនសម្រាប់ករណីបន្ទាន់។
- ជំរុញកិច្ចសន្ទនាចុះឡើង ដើម្បីលើកកម្ពស់គណនេយ្យភាព និងតម្លាភាព ក៏ដូចជា ការប្រាស្រ័យទាក់ទងតាមខ្សែបញ្ឈរ និងខ្សែផ្តេក ដើម្បីឲ្យមានការសម្របសម្រួលកាន់តែប្រសើររវាងមន្ទីរក្រសួងរដ្ឋដែលពាក់ព័ន្ធនឹងទឹក ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងមហន្តរាយ។
- លើកកម្ពស់លទ្ធភាពស្មើគ្នា ក្នុងការបានប្រើប្រាស់ធនធានសំខាន់ៗ ដោយផ្តោតជាពិសេសលើប្រជាជនខ្វះខាតសិទ្ធិអំណាច។
- សម្រួលដល់លទ្ធភាពទទួលបានព័ត៌មានសំខាន់ៗ ស្តីពីបរិមាណទឹកដែលមាន និងចម្លើយតបផ្នែកបន្សាំសម្រាប់ប្រជាជន សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

## ឯកសារយោង


APN (Asia-Pacific Network). 2011. *Climate Change Governance in the Asia-Pacific Region: Agency, Accountability, and Adaptiveness*. Asia-Pacific Network for Global Change Research.

Berkes F., and C. Folke. 1998. "Linking Social and Ecological Systems for Resilience and Sustainability." In *Linking Social and Ecological Systems*, edited by F. Berkes, C. Folke and J. Colding. Cambridge: University Press.

Biermann, Frank, Michele M. Betsill, Joyeeta Gupta, Norichika Kanie, Louis Lebel, Diana Liverman, Heike Schroeder, Bernd Siebenhüner and Ruben Zondervan. 2010. "Earth System Governance: A Research Framework." *International Environmental Agreements: Politics, Law and Economics* 10(4): 277-298.

Chheat Sreang, Lun Pide, Kim Sedara, Heng Seiha, Sok Sethea and Chhoun Nareth. 2011. *A Baseline Survey of Subnational Government: Towards a Better Understanding of Decentralisation and Deconcentration in Cambodia*. CDRI Special Report No. 12. Phnom Penh: CDRI.

MOE (Ministry of Environment). 2012. RGC Planning and Climate Change/Disaster Risk Reduction: Inventory of National and Sector Plans, Pilot Program for Climate Resilience (PPCR) Project – Phase I, Components 1 & 2: Mainstreaming Climate Resilience into Development Planning at the National and Sub-National Levels Funded by the Strategic Climate Fund Trust Fund (IBRD Grant TF097459-KH, managed by IDA) 5th Mandate Royal Government of Cambodia's Rectangular Strategy Phase III (RSP III; 2014-2018) approved by the National Assembly on 24 September 2013.

Rusten, Caroline, Kim Sedara, Eng Netra and Pak Kimchoeun. 2004. *The Challenges of Decentralisation Design in Cambodia*. Phnom Penh: CDRI.

Sam Sreymom, Kim Sour, Nong Monin and Sarom Molideth. 2015. "Vulnerability Assessment in the Three Catchments." In *Climate Change and Water Governance in Cambodia: Challenges and Perspectives for Water Security and Climate Change in Selected Catchments,* edited by Sam Sreymom and Pech Sokhem, 56-88. Phnom Penh: CDRI.

UNDP (United Nations Development Programme). 2013. *Cambodia: Strengthening the Resilience of Cambodian Rural Livelihoods and Subnational Government System to Climate Risks and Variability, GEF ID 5419*. Phnom Penh: UNDP.

Walker, Brian, Crawford S. Holling, Stephen R. Carpenter and Ann Kinzig. 2004. "Resilience, Adaptability and Transformability in Social-Ecological Systems." *Ecology and Society* 9(2): 5.

Water Governance Facility. "What is Water Governance." http://watergovernance.org/water-governance/.

# ប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថានៈ បទពិសោធន៍ទទួលបានពីគម្រោងសាកល្បងនៃកម្មវិធីរេដ+

## សេចក្ដីផ្ដើម

អនុសញ្ញាក្របខ័ណ្ឌនៃ អង្គការសហប្រជាជាតិស្ដីពី ការប្រែប្រួលធាតុអាកាស (UNFCCC 2013) បានចែងថា រេដ+ (REDD+) សំដៅដល់គោលនយោបាយ និងវិធានការទាំងឡាយ ដើម្បីកាត់បន្ថយការបំភាយឧស្ម័ន ពីការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើ និងលើកកម្ពស់តួនាទីធ្វើការអភិរក្សគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងបង្កើនស្តុកកាបូននៃព្រៃឈើនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ (រេដ+)។ តាំងពីការបំផុសគំនិតផ្ដួចផ្ដើមក្នុងឆ្នាំ២០១០ មក ប្រធានបទដែលមានការស្រាវជ្រាវច្រើនជាងគេមួយលើ រេដ+ គឺផលប៉ះពាល់ និងអត្ថប្រយោជន៍នៃការអភិវឌ្ឍ និងអនុវត្ត រេដ+ សម្រាប់បរិស្ថាន និងសង្គម (Angelsewn 2010; Nguon and Kulakowski 2013; Peskett and Todd 2013)។ ហានិភ័យ និងអត្ថប្រយោជន៍អាចកើតមានឡើងនេះ គេបានលើកមកពិភាក្សា ក្នុងបំណងផ្ដល់នូវប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថាន ឲ្យបានគ្រប់គ្រាន់។ កម្មវិធី UN-REDD របស់អង្គការសហប្រជាជាតិ (2015) បានឲ្យនិយមន័យប្រព័ន្ធធានាសុវត្ថិភាពថាជា បណ្ដាដំណើរការ ឬគោលនយោបាយកំណត់ឡើងដើម្បី បញ្ចៀស ឬកាត់បន្ថយហានិភ័យអាចកើតមានផលប៉ះពាល់អវិជ្ជមានលើសង្គម និងបរិស្ថាន និងដើម្បីធានាឲ្យការអនុវត្ត រេដ+ ផ្ដល់នូវអត្ថប្រយោជន៍សម្រាប់សង្គម និងបរិស្ថាន។

ប្រព័ន្ធធានាសុវត្ថិភាព អាចចែកចេញជាពីរក្រុម។ ក្រុមទី១ រួមមាន ឯកសារស្ដីពីការសម្រេចចិត្តផ្សេងៗ ដែល UNFCCC បានអនុម័តឡើង និងមានជាអាទិ៍ កិច្ចព្រមព្រៀង Cancun Agreements, សេចក្ដីណែនាំ Durban Guidance, ក្របខ័ណ្ឌ Warsaw Framework សម្រាប់ រេដ+ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាពេលថ្មីៗនេះ។ ក្រុមទី២ រួមមាន ការតម្រូវផ្សេងៗដែលបានកំណត់ឡើងនៅក្រៅដំណើរការ UNFCCC ដោយអ្នកគាំទ្រទីផ្សារកាបូនស្ម័គ្រចិត្ត ដូចជា Verified Carbon Standard (VCS) និង Climate, Community and Biodiversity Standard (CCBS) (Nguon and Chhun 2015) ជាដើម។

ក្រោយកិច្ចប្រជុំ UNFCCC ឆ្នាំ២០០៧ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចអនុវត្តគម្រោងសាកល្បង រេដ+ ដោយមានការអនុម័តយល់ព្រមលើ សហគមន៍ព្រៃឈើឧត្តរមានជ័យ ក្នុងឆ្នាំ២០០៨ និង ព្រៃការពារសីមា ក្នុងខេត្តមណ្ឌលគិរី ក្នុងឆ្នាំ២០០៩។ គម្រោងទាំងពីរមានដាក់អនុវត្តនូវ សំណុំខ្លះនៃប្រព័ន្ធធានាសុវត្ថិភាព សង្គម និងបរិស្ថាន សំដៅបំពេញតាមការតម្រូវផ្សេងៗនៅក្នុង VCS និង CCBS។ ដូច្នេះ អត្ថបទនេះមានគោលដៅមិនមែនធ្វើការវាយតម្លៃលើការដាក់អនុវត្ត ប្រព័ន្ធធានាសុវត្ថិភាពរបស់ UNFCCC នៅកម្ពុជា នោះទេ ប៉ុន្តែដើម្បីពិនិត្យ និងប្រៀបធៀបបទពិសោធន៍នៃគម្រោងទាំងពីរ ក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ VCS និង CCBS។ ដើម្បីបំភ្លឺបន្ថែមពីបែបបទដែលវិធានការទាំងនេះ ជួយកាត់បន្ថយហានិភ័យផ្សេងៗ ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រ បង្កើតឡើងដោយ Roe et al. (2013) ដែលបានបែងចែកប្រព័ន្ធធានាសុវត្ថិភាព រេដ+ ជាបីប្រភេទគឺ សង្គម បរិស្ថាន និងនីតិវិធីផ្លូវការ។

## វិធីសាស្ត្រ

ការសិក្សានេះ ប្រើប្រាស់ការវិភាគប្រៀបធៀបបែបគុណភាព។ ព័ត៌មានបានប្រមូលយកតាមការធ្វើសម្ភាសន៍ជាមួយ អ្នកផ្ដល់ព័ត៌មានគន្លឹះ ការពិភាក្សាតាមក្រុមស្នូល និងការសិក្សាស្រាវជ្រាវលើឯកសារមានស្រាប់ ដូចជា របាយការណ៍រដ្ឋាភិបាល សារព័ត៌មាន អត្ថបទសង្ខេបគោលនយោបាយ និងការសិក្សាពីភាពអាចធ្វើបាន ជាដើម។ ទិន្នន័យជាក់ស្ដែងស្ដីពីគម្រោងសាកល្បងទាំងពីរ បានប្រមូលយកតាមការចុះសិក្សាដល់កន្លែងចំនួន ២លើកគឺ ពីខែតុលា ដល់ ធ្នូ ២០១៣ និង ពីខែមករា ដល់ កក្កដា ២០១៥។ ការចុះសិក្សាដល់កន្លែងទាំងនេះ ទទួលបានជំនួយជាអំណោយពី បណ្ដាញស្រាវជ្រាវមេគង្គប្រកបដោយចីរភាព (SUMERNET) ជំហានទី៣ របស់វិទ្យាស្ថាន Stockholm Environment Institute។

សរុបទាំងអស់មក ក្រុមស្រាវជ្រាវបានធ្វើ ៥០សម្ភាសន៍ពាក់កណ្ដាលរៀបរយ ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះដែលតំណាងឲ្យ ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ការពិភាក្សាតាមក្រុមស្នូល បានអនុវត្តឡើងជាមួយ អ្នកតំណាងមកពី ១៣សហគមន៍ព្រៃឈើ ក្នុងខេត្តឧត្តរមានជ័យ និង ២០សហគមន៍ជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគិរី។ ក្នុងការវិភាគទិន្នន័យ ក្រុមស្រាវជ្រាវបានប្រើកម្មវិធីកុំព្យូទ័រសម្រាប់វិភាគទិន្នន័យ NVivo ១០ ជាឧបករណ៍ជំនួយ ហើយបានប្រើគួបផ្សំគ្នានូវ មុខងារជាច្រើននៃកម្មវិធីកុំព្យូទ័រនេះ ដើម្បីដាក់លេខកូដជាទូទៅ និងធ្វើការស្រាវជ្រាវជាក់លាក់មួយចំនួនលើទិន្នន័យមានដាក់លេខកូដរួចហើយ ដែលក្រុមស្រាវជ្រាវ

---

អត្ថបទនេះ ចងក្រងឡើងដោយបណ្ឌិត ងួន ភក្ដី អ្នកសម្របសម្រួលផ្នែកស្រាវជ្រាវ ដេប៉ាតឺម៉ង់សិក្សាអន្តរជាតិ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង លោក ឈុន ឌីលុច ប្រធានការិយាល័យឥណទានកាបូនព្រៃឈើ និងការប្រែប្រួលអាកាសធាតុ នៃរដ្ឋបាលព្រៃឈើ។ សូមយោងអត្ថបទនេះថា៖ Nguon Pheakkdey and Chhun Delux. 2016. "Social and Environmental Safeguards: Lessons from Cambodia REDD+ Pilot Projects." *Cambodia Development Review* 20(2): 10-14.

បានរៀបចំផ្តុំវាក្រោម ៣ប្រធានបទគឺ សង្គម បរិស្ថាន និងនីតិវិធីផ្លូវការ (Roe et al. 2013)។

## និយមន័យពាក្យគន្លឹះ

វាក្យស័ព្ទខ្លះ ដែលយកមកប្រើនៅក្នុងឯកសារនេះ មានន័យជាក់លាក់សម្រាប់បញ្ហា រេដ+[1]។ UNFCCC (2014) បានកំណត់និយមន័យពាក្យទាំងនោះដូចតទៅ៖

- **ការបង្កបន្លាស់ទី (displacement)**៖ កត្តាជំរុញការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ត្រូវបានផ្លាស់ទីចេញពីតំបន់មានគម្រោង រេដ+ ទៅកាន់តំបន់ដទៃទៀតដែលគ្មានគម្រោងនេះ។
- **ការជ្រាបចេញ**៖ កំណើនណាមួយនៃ ការបំភាយឧស្ម័នផ្ទះកញ្ចក់ ទៅក្រៅតំបន់មានគម្រោង រេដ+ ដែលជាលទ្ធផលនៃសកម្មភាពគម្រោង។
- **ភាពអចិន្ត្រៃយ៍**៖ កាបូន ត្រូវបានស្តុកទុកជាបណ្តោះអាសន្នប៉ុណ្ណោះ ហើយក្រោយមកនឹងត្រូវបញ្ចេញទៅវិញទៀត ទៅក្នុងបរិយាកាស។
- **ការប្រែប្រួលបញ្ច្រាស (reversal)**៖ កង្វះការធានាគួរឲ្យជឿជាក់ថា សកម្មភាពប្រើប្រាស់ដីពីដើមទី នឹងមិនវិលទៅរកសភាពដើមវិញទេ ក្រោយពេលគម្រោងចប់អស់។

## ប្រព័ន្ធធានាសុវត្ថិភាពសហគមន៍ព្រៃឈើឧត្តរមានជ័យ

គម្រោងសាកល្បង រេដ+ នៅសហគមន៍ព្រៃឈើឧត្តរមានជ័យ ស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា។ គម្រោងនេះ គ្របដណ្តប់លើ ១៣សហគមន៍ព្រៃឈើ មានផ្ទៃដីសរុប ៦៤.៣១៨ហិកតា និង ៥៨ភូមិ ហើយមានប្រជាជនទាំងអស់ប្រមាណ ១០.០០០គ្រួសារ។ តាំងពីឆ្នាំ២០០៩ មក អង្គការផេកកម្ពុជា (Pact Cambodia) បានបម្រើការជាដៃគូអនុវត្តគម្រោង ដោយរួមសហការជាមួយ រដ្ឋបាលព្រៃឈើ ក្រុមសហគមន៍ព្រៃឈើ ទាំង ១៣ក្រុមហ៊ុន Terra Global Capital សមាគមអភិវឌ្ឍន៍កុមារ សហគមន៍ព្រៃឈើសង្ឃរុក្ខវ័ន្ត និងអាជ្ញាធរមូលដ្ឋាន (Nguon 2014)។

គម្រោងនេះ បានធានានូវសិទ្ធិកាន់កាប់ដីធ្លីសម្រាប់សហគមន៍ព្រៃឈើ ១៣កន្លែង ដោយមានកិច្ចព្រមព្រៀងរយៈពេល ១៥ឆ្នាំ រវាងរដ្ឋបាលព្រៃឈើ នឹងក្រុមសហគមន៍ព្រៃឈើ។ កិច្ចការនេះ ត្រូវមានកិច្ចប្រឹងប្រែងខ្លាំងក្លា ធ្វើការប្រមូលផ្តុំអ្នកពាក់ព័ន្ធនានា ផ្តល់ការបណ្តុះបណ្តាល និងជួយបង្រៀនសហគមន៍ ឆ្លងតាមដំណើរការ និងការតម្រូវផ្សេងៗ ដើម្បីផ្តល់ភាពស្របច្បាប់ដល់សហគមន៍ព្រៃឈើ។ ស្របតាមកិច្ចព្រមព្រៀងស្តីពីសហគមន៍ព្រៃឈើ គឺមានការទទួលស្គាល់សិទ្ធិរបស់សហគមន៍ក្នុងការប្រើប្រាស់សម្រាប់ការចិញ្ចឹមជីវិតនូវ ផល និងអនុផលព្រៃឈើ (NTFP)។ មានការអនុញ្ញាតផងដែរឲ្យអ្នកភូមិ បន្តប្រើប្រាស់ដីកសិកម្មដែលមានស្រាប់ នៅក្នុងព្រំប្រទល់នៃសហគមន៍ព្រៃឈើ ប៉ុន្តែមិនអនុញ្ញាតឲ្យពង្រីកដីទាំងនោះទេ។

កន្លងមកមានការប្រជុំពិគ្រោះយោបល់ជាច្រើន ដើម្បីធានាថា ម្ចាស់ដីទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយពេញចិត្តចូលរួមក្នុងគម្រោងនេះ។ អ្នកគាំទ្រគម្រោងបានរចនារៀបចំដំណើរការពិគ្រោះយោបល់របស់ខ្លួន ដោយផ្អែកលើគោលការណ៍ មានការយល់ព្រមជាមុន មានព័ត៌មានគ្រប់គ្រាន់ និងសេរីភាពក្នុងការចូលរួម (FPIC)។ ឧទាហរណ៍ គម្រោងនេះបានរៀបចំសិក្ខាសាលាជាច្រើននៅក្នុងប្រមាណ ៥០ភូមិ និងនៅកម្រិតស្រុក និងខេត្ត ដើម្បីពង្រីកការយល់ដឹងរបស់សហគមន៍ អំពី រេដ+ និងសកម្មភាពគម្រោង ព្រមទាំងផ្តល់ឲ្យពួកគេនូវឱកាស និងពេលវេលាគ្រប់គ្រាន់ ដើម្បីសម្រេចចិត្តចូលរួម ឬមិនចូលរួមក្នុងគម្រោង។ ជាលទ្ធផល ទាំង ១៣ក្រុមសហគមន៍ព្រៃឈើ បានយល់ព្រមដោយផ្ទាល់មាត់ចូលរួមក្នុងគម្រោង។

ទិដ្ឋភាពគួរឲ្យកត់សំគាល់មួយនៃ ដំណើរការពិគ្រោះយោបល់ គឺអ្នកគាំទ្រគម្រោង បានផ្តល់ព័ត៌មានទៅសហគមន៍នានាថា សហគមន៍នឹងទទួលបានការផ្តល់ប្រាក់ជាច្រើនពីគម្រោង។ កត្តានេះ អាចជាហេតុផលចម្បងមួយនៃការសម្រេចចិត្តចូលរួមរបស់សហគមន៍។ ការប្រាប់សហគមន៍ពីការផ្តល់ប្រាក់ពីគម្រោង រេដ+ បានបង្កើនការរំពឹងទុកពីការទទួលបានអត្ថប្រយោជន៍ជាប្រាក់កាស។ ប៉ុន្តែការយឺតយ៉ាវក្នុងការទទួលបានការផ្តល់ប្រាក់ពីគម្រោង រេដ+ បានបង្កើតជាបញ្ហាប្រឈមក្នុងការធានាឲ្យមានការបន្តគាំទ្រ និងចូលរួមក្នុងសកម្មភាពគម្រោងពីសំណាក់ សមាជិកសហគមន៍ព្រៃឈើ។

គម្រោងនេះដាក់អនុវត្តវិធានការជាច្រើន ដើម្បីធានាសុវត្ថិភាព និងឃ្លាំមើលជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ព្រៃស្រោង និងព្រៃល្បោះស្ងួត ដោយយកចិត្តទុកដាក់ជាពិសេសទៅលើ តំបន់អភិរក្សមានតម្លៃខ្ពស់ ដែលសំខាន់សម្រាប់ពូជសត្វព្រៃកម្រៗ។ យុទ្ធសាស្ត្រនេះ ត្រូវមានការបំផុសការយល់ដឹងឲ្យបានកាន់តែច្រើន ក្នុងចំណោមសហគមន៍មូលដ្ឋានអំពី តម្លៃនៃជីវៈចម្រុះ ក៏ដូចជា ការលើកកម្ពស់ការដើរល្បាត និងជំនាញស្តារជម្រកសត្វឡើងវិញ ដើម្បីការពារព្រៃឈើទល់នឹងការកាប់ឈើ ការបរបាញ់ខុសច្បាប់ និងភ្លើងឆេះព្រៃ ព្រមទាំងទប់ស្កាត់ការរេចរឹលជម្រកសត្វព្រៃសំខាន់ៗ។ ទោះយ៉ាងណាក្តី គម្រោងនេះ មិនមានវិធានការច្បាស់លាស់ សម្រាប់គ្រប់គ្រងហានិភ័យនៃការប្រែប្រួលបញ្ច្រាស និងការបង្កបន្លាស់ទីនោះឡើយ។ ជាលទ្ធផល គម្រោងនេះកំពុងប្រឈមនឹង ហានិភ័យនៃការប្រែប្រួលបញ្ច្រាសវិញ ដោយសហគមន៍ខ្លះកំពុងរងការសម្លុតគំរាម ពីសំណាក់អ្នកកាប់ឈើប្រដាប់ដោយអាវុធ។ ម្យ៉ាងវិញទៀត ក៏មិនទាន់មានការកំណត់ច្បាស់ដែរថា អ្នកណាទទួលខុសត្រូវលើការការពារព្រៃឈើក្នុងតំបន់ទ្រនាប់នៅព័ទ្ធជុំវិញព្រៃសហគមន៍។

ទោះបីជាគម្រោងនេះ មានអ្នកពាក់ព័ន្ធជាច្រើនក្រុមចូលរួមក្តី ប៉ុន្តែនៅមានការងារត្រូវធ្វើថែមទៀត ដើម្បីជំរុញសមធម៌យេនឌ័រ និងពង្រឹងការចូលរួមរបស់ស្ត្រី។ តំណាងសហគមន៍ភាគច្រើនលើសលុបជាបុរស ព្រោះក្នុងចំណោមតំណាងសហគមន៍ព្រៃឈើទាំង១៣ មានតែមួយរូបប៉ុណ្ណោះ ជាស្ត្រី។ តួលេខនេះ បង្ហាញពីតម្រូវការពិនិត្យអង្កេតថែមទៀត ដើម្បី

1 សម្រាប់បញ្ជីពេញលេញនៃវាក្យស័ព្ទ REDD+ សូមរកមើលនៅក្នុង UNFCCC 2014។

ស្រាវជ្រាវរកមើលថា តើសមភាពយេនឌ័រមានការទទួលយក និងគោរពតាមប៉ុណ្ណា ក្នុងពេលធ្វើការសម្រេចចិត្តលើចំណុចសំខាន់ៗនៃគម្រោង។

តំណាងសហគមន៍ព្រៃឈើ បានរាយការណ៍ថា ការតវ៉ា និងការមិនពេញចិត្តផ្សេងៗ តែងបានដាក់ជូនទៅដល់អ្នកទ្រទ្រង់គម្រោង។ ប៉ុន្តែក្នុងពេលកន្លងមក អ្នកតវ៉ាមិនទាន់ពេញចិត្តទេនឹងសមត្ថភាពមានកម្រិតរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហាដែលប្រជាជនមូលដ្ឋានត្រូវប្រឈមមុខ។ តំណាងសហគមន៍ព្រៃឈើបានប្រាប់ទៀតថា ដោយសារកង្វះខាតចំណេះដឹង និងថវិកា ពួកគេក៏មិនអាចស្វែងរកជំនួយទ្រទ្រង់ពីភាគីទី៣ ដើម្បីជួយបញ្ជាក់ពីការមិនពេញចិត្តរបស់ខ្លួន។ លទ្ធផលរកឃើញនេះ បានគូសបញ្ជាក់ពីតម្រូវការពិនិត្យអង្កេតបន្ថែមលើបញ្ហានេះ។

## ប្រព័ន្ធធានាសុវត្ថិភាពតំបន់ព្រៃការពារសីមា

គម្រោងសាកល្បង រេដ+ ព្រៃការពារសីមា សំដៅបំផុសជំនួយគាំទ្រពីសាធារណជន និងការចូលរួមក្នុងកិច្ចការពារព្រៃឈើមានវ័យចំណាស់ដែលមានសារៈសំខាន់ សម្រាប់ប្រព័ន្ធអេកូឡូស៊ី នៅក្នុងតំបន់ស្នូលមួយទំហំ ១៨០.៥១៥ហិកតា ក្នុងខេត្តមណ្ឌលគិរី នៅភាគខាងកើតនៃប្រទេសកម្ពុជា។ តំបន់នេះល្បីល្បាញថា សម្បូរពូជសត្វព្រៃ ដែលមានសារៈសំខាន់សម្រាប់ពិភពលោក។ ឯកសារគម្រោង (FA and WCS 2011) បញ្ជាក់ថា នៅក្នុងតំបន់គម្រោងមាន ២០ភូមិ ដែលជាលំនៅរបស់ជនជាតិដើមភាគតិចពូងប្រមាណ ១០.០០០នាក់។ នៅខែឧសភា ២០១៦ គម្រោង រេដ+ សីមា បានឆ្លងផុតដំណាក់កាលបញ្ជាក់ភាពអាចទទួលយកបាន យោងតាមលក្ខខណ្ឌតម្រូវរបស់ VCS និង CCBA ហើយបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលផ្ទៀងផ្ទាត់មើល (CCBS 2016)។ ដើម្បីអាចលក់ឥណទានកាបូន គម្រោង រេដ+ ដោយស្ម័គ្រចិត្ត ត្រូវឆ្លងឲ្យផុតទាំង ដំណាក់កាលបញ្ជាក់ភាពអាចទទួលយកបាន និងការផ្ទៀងផ្ទាត់មើល។ ថ្វីបើរយៈពេលទទួលបានឥណទាន នឹងបន្តទៅមុខរហូតដល់ ៦០ឆ្នាំ ប៉ុន្តែគេប៉ាន់ស្មានថា គម្រោងនេះអាចជួយកាត់បន្ថយបន្សាយឧស្ម័នកាបូនិកដល់ប្រមាណ ៥៨លានតោនក្នុងរយៈពេល ១០ឆ្នាំដំបូងរបស់វា (FA and WCS 2011)។

ឯកសារគម្រោងមានចែងច្បាស់ថា សហគមន៍មានសិទ្ធិប្រើប្រាស់និងអាស្រ័យផល (usufructory rights) លើផលិតផលឈើ និងអនុផលព្រៃឈើ និងអាចបន្តធ្វើកសិកម្មចិញ្ចឹមជីវិតនៅលើដីដែលខ្លួនបានកាន់កាប់ដោយស្របច្បាប់។ គម្រោងក៏បានធានានូវសិទ្ធិកាន់កាប់លើ ដីកសិកម្ម ដីទំនេរ និង ដីលំនៅដ្ឋានរបស់ពួកគេដែរ។ ដំណើរការនេះរួមមាន ការគូរផែនទីដីសហគមន៍ជាមួយសហគមន៍ និងការបង្កើតឯកសារច្បាប់សម្រាប់ស្នើសុំកម្មសិទ្ធិដីសហគមន៍ពីរដ្ឋាភិបាល។ ដូច្នេះមិនត្រូវមានការបង្ខំឲ្យអ្នកកាន់កាប់ដីលំនៅដ្ឋាន ឬដីស្រែចំការ ដោយស្របច្បាប់ ផ្លាស់ទីទៅកន្លែងមួយទៀតនោះទេ។ ទោះយ៉ាងនេះក្តី អ្នកផ្តល់ព័ត៌មាននានាបានប្រាប់ពីក្តីបារម្ភថា ម្ចាស់ដី និងអ្នករស់នៅក្នុងមូលដ្ឋាន អាចត្រូវគេចាត់ទុកតាមផ្លូវច្បាប់ដោយច្រឡំថា ជាអ្នកមកតាំងលំនៅក្រៅផ្លូវការ ឬអ្នកមកទន្ទ្រានយកដី។ ហេតុនេះហើយ ពួកគាត់ខ្លាចអាជ្ញាធរធ្វើការឃាត់ខ្លួនពីបទកាន់កាប់ដីរដ្ឋ ឬដីសហគមន៍ដោយខុសច្បាប់ បណ្តេញគាត់ចេញពីដីធ្លីគាត់កាន់កាប់ដោយគ្មានផ្តល់សំណង ប្តឹងចោទប្រកាន់លើរូបគាត់ ឬដាក់ទោសគាត់ឲ្យជាប់ពន្ធនាគារ។

ទោះបីមានការទទួលស្គាល់សិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងដីធ្លី និងរក្សាទម្លាប់កសិកម្មបែបប្រពៃណីរបស់ខ្លួនក៏ដោយ ក៏មានការកំណត់ថា កសិកម្មពនេចរ ជាការគំរាមកំហែងចម្បងមួយដែលបង្កការរេចរឹលបាត់បង់ព្រៃឈើ និងដែលគម្រោងនេះព្យាយាមលុបបំបាត់ចោល។ អ្នកផ្តល់ព័ត៌មាននានា បានរាយការណ៍ថា លំហូរចូលជនចំណាកស្រុកដ៏ច្រើន បានបង្កការច្របូកច្របល់មិនដឹងថា តើប្រជាជនមូលដ្ឋាន (ប្រជាជនជនជាតិដើមភាគតិច) ឬអ្នកមកពីក្រៅ ដែលកំពុងធ្វើកសិកម្មពនេចរសព្វថ្ងៃ។ ហេតុនេះត្រូវធ្វើការពិនិត្យអង្កេតជាក់ស្តែងលើ សមាសភាពសហគមន៍មូលដ្ឋាន ដើម្បីធានាថា ការអនុវត្តគម្រោងមិនប៉ះពាល់ដល់សកម្មភាព កសិកម្មពនេចរតាមទម្លាប់របស់ប្រជាជនជនជាតិដើមភាគតិច។

គម្រោងនេះ ក៏បានអនុវត្តតាមគោលការណ៍ មានការយល់ព្រមជាមុន មានព័ត៌មានគ្រប់គ្រាន់ និងសេរីភាពក្នុងការចូលរួម (FPIC) ផងដែរ។ ការពិនិត្យអង្កេតដល់កន្លែងបានបង្ហាញជាទូទៅពី ចំណេះដឹងតិចលើខ្លឹមសារនៃកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ក្នុងចំណោមសហគមន៍នានា រួមទាំងបុគ្គលដែលយល់ព្រមលើការអនុវត្តគម្រោង រេដ+ ដោយបានផ្តិតមេដៃ ឬចុះហត្ថលេខា។ តួយ៉ាង នៅពេលមានការសាកសួរពីចំណុចសំខាន់ៗនៃ កិច្ចព្រមព្រៀង (ឧទាហរណ៍ សេចក្តីចែងពីការយល់ព្រម រយៈពេល យន្តការដោះស្រាយ-ជំទាស់តវ៉ា ក្នុងករណីភាគីណាមួយ មិនអនុវត្តតាមទំនួលខុសត្រូវរបស់ខ្លួន) តំណាងសហគមន៍ជនជាតិដើមភាគតិច មិនអាចផ្តល់ព័ត៌មានទាំងនេះបានឡើយ។ ការបកស្រាយសាមញ្ញមួយ គឺអាចមកពីពួកគាត់បានភ្លេចពីចំណុចសំខាន់ៗទាំងនោះ ឬក៏ក្រុមស្រាវជ្រាវលើកសំណួរមិនបានត្រឹមត្រូវ។ ទោះជាដូច្នេះក្តី លទ្ធផលសិក្សាបង្ហាញថា ត្រូវធ្វើការបន្ថែមទៀតលើដំណើរការ FPIC នេះ មុនពេលមានការស្នើសុំ និងការផ្តល់ការយល់ព្រម។

គម្រោងនេះព្យាយាមរក្សាប្រភេទផ្សេងៗនៃគម្របព្រៃឈើ និងបង្កើនចំនួនសត្វព្រៃដែលមានសារៈសំខាន់ សម្រាប់ការអភិរក្ស។ ក្នុងគោលដៅនេះ គម្រោងព្យាយាមកាត់បន្ថយការគំរាមកំហែងផ្នែកបរិស្ថាន ដូចជា ការបាត់បង់ជម្រកសត្វព្រៃ ការបរបាញ់តាមគ្រប់រូបភាព ការកាប់ឈើដោយជ្រើសរើស និងការប្រមូលផលនិងអនុផលព្រៃឈើច្រើនហួសប្រមាណ។ ឯកសារគម្រោងបង្ហាញថា គម្រោងព្យាយាមសម្រេចគោលដៅនេះ មួយចំណែកតាមរយៈប្រពលវប្បកម្មកសិកម្ម និងមួយចំណែកទៀតតាមការដាក់បញ្ចូលការប្រើប្រាស់ដោយមនុស្សនូវ ដីមិនមែនដីព្រៃស្ថិតក្នុងតំបន់គម្រោង ទៅក្នុងតំបន់គ្រប់គ្រងការជ្រាបចេញ។ តំបន់រងការជ្រាបចេញ រួមមាន ដីព្រៃទាំងឡាយដែលត្រូវបានកែប្រែទៅបម្រើការប្រើប្រាស់មិនមែនជាព្រៃឈើ ឬត្រូវបានកាប់ឆ្ការគិតត្រឹមឆ្នាំ២០១០ ក្នុងចម្ងាយមិនលើសពី ៣គីឡូម៉ែត្រពីកន្លែងតាំងលំនៅដ្ឋានរបស់អ្នកស្រុក។ គម្រោងនេះអនុវត្តសកម្មភាព

គ្រប់គ្រងការជ្រាបចេញមួយចំនួន ដូចជា អេកូទេសចរណ៍ និងការគ្រប់គ្រងអនុផលព្រៃឈើ នៅក្នុងកន្លែងមានព្រៃឈើនៃតំបន់គម្រោង និងតំបន់ទ្រនាប់មានការជ្រាបចេញ។ ទោះយ៉ាងនេះក្តី អ្នកផ្តល់សម្ភាសន៍បានប្រាប់ថា ការកាប់ឈើខុសច្បាប់ដែលអនុវត្តភាគច្រើនដោយអ្នកមកពីក្រៅ កំពុងបន្តទៅមុខក្នុងកម្រិតគួរឲ្យបារម្ភនៅក្នុងភូមិរបស់គាត់។ ហេតុនេះ អ្នកទ្រទ្រង់គម្រោងត្រូវធ្វើការពិនិត្យអង្កេត និងឆ្លើយតបទៅនឹងក្តីបារម្ភទាំងនេះ ព្រោះបរាជ័យក្នុងការបញ្ឈប់ការកាប់ឈើខុសច្បាប់នេះអាចបង្កគ្រោះថ្នាក់នៃការជ្រាបចេញសកម្មភាពនេះ ការប្រែប្រួលបញ្ច្រាស និងភាពមិនអាចគង់វង្សជាអចិន្ត្រៃយ៍។

អ្នកទ្រទ្រង់គម្រោង បានជំរុញជាហូរហែនូវអ្នកពាក់ព័ន្ធជាច្រើន ជាពិសេសអ្នកនៅតាមតំបន់គម្រោង ឲ្យចូលរួមក្នុងដំណើរការពិគ្រោះយោបល់យ៉ាងធំទូលាយលើប្រធានបទផ្សេងៗទាក់ទងនឹងគម្រោង រេដ+ និងមិនទាក់ទងនឹងគម្រោង រេដ+។ ទោះយ៉ាងនេះក្តី សហគមន៍បានលើកបញ្ហាពីរឡើង ក្នុងពេលធ្វើការពិភាក្សាតាមក្រុមស្នូល។ ទី១ ពួកគេចង្អុលបង្ហាញថា ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទៅមុខទៀត គួរផ្តោតលើសកម្មភាព ឬឧបសគ្គក្នុងការអនុវត្តគម្រោងរេដ+។ តួយ៉ាង អ្នកផ្តល់ព័ត៌មានចង់ដឹងថា តើទម្លាប់ធ្វើកសិកម្មពនេចរនាពេលបច្ចុប្បន្នរបស់គាត់នឹងត្រូវហាមឃាត់ ឬយ៉ាងណា។ ទី២ ពួកគាត់ បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃ ការបង្កើនការចូលរួមចំណែករបស់ស្ត្រីនៅក្នុងដំណើរការពិគ្រោះយោបល់។

អ្នកទ្រទ្រង់គម្រោងបានណែនាំឲ្យប្រើនូវ យន្តការជំទាស់តវ៉ាមួយដែលអនុញ្ញាតឲ្យប្រជាជនមូលដ្ឋាន ដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅដល់ក្រុមអនុវត្តគម្រោង ដើម្បីធ្វើការវាយតម្លៃ និងដោះស្រាយ។ ក្រុមប្រឹក្សាឃុំក្នុងតំបន់គម្រោង ក៏មានភារកិច្ចតាមផ្លូវច្បាប់ ត្រូវទទួលយកបណ្តឹងរបស់អ្នកស្រុកលើបញ្ហាគ្រប់បែបយ៉ាង រួចហើយ ឬមួយបញ្ជូនបណ្តឹងទាំងនោះទៅកាន់ផ្នែកមានសមត្ថកិច្ចសមស្របតាមបណ្តឹង ឬមួយព្យាយាមដោះស្រាយវាដោយផ្ទាល់ ជាទូទៅតាមរយៈការសម្រុះសម្រួលរវាងភាគីរងការប៉ះពាល់។ ស្រដៀងគ្នានឹងសហគមន៍នៅឧត្តរមានជ័យដែរ នៅពេលសាកសួរពី បញ្ហាដែលពួកគេកំពុងប្រឈមមុខក្នុងការគ្រប់គ្រងព្រៃឈើនៅក្នុងភូមិខ្លួន សហគមន៍ជនជាតិដើមភាគតិចនៅសីមា បានពណ៌នាយ៉ាងក្បោះក្បាយពីរបៀបដែលអ្នកមកពីក្រៅស្រុក បានចូលមកកាប់ព្រៃឈើរបស់គាត់ដោយខុសច្បាប់។ អ្នកផ្តល់ព័ត៌មានម្នាក់បានប្រាប់ថា ទោះបីពួកគាត់បានដាក់បណ្តឹងតវ៉ាទៅអាជ្ញាធរទទួលខុសត្រូវខាងព្រៃឈើក៏ដោយ ក៏សកម្មភាពកាប់ឈើខុសច្បាប់ទាំងនេះ មិនទាន់មានការដោះស្រាយឲ្យបានសមស្របនៅឡើយ។ បញ្ហានេះ បានបង្កើតនូវមន្ទិលសង្ស័យជាច្រើនក្នុងចំណោមសហគមន៍នានា អំពីប្រសិទ្ធភាពនៃគម្រោង រេដ+ ក្នុងការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ បង្កឡើងដោយអ្នកមកពីក្រៅស្រុក។ ប្រសិនបើការគំរាមកំហែងនេះ មិនអាចដោះស្រាយបានដោយសមស្របនោះទេ គម្រោងរេដ+ អាចជួបហានិភ័យនៃការជ្រាបចេញ ការមិនគង់វង្សជាអចិន្ត្រៃយ៍ និងការប្រែប្រួលបញ្ច្រាសវិញ។

## សេចក្តីសន្និដ្ឋាន

UNFCCC (2013) បានកំណត់ឲ្យបណ្តាប្រទេសចូលរួមក្នុងគម្រោង រេដ+ រួមទាំងកម្ពុជាផង បង្កើតប្រព័ន្ធធានាសុវត្ថិភាពថ្នាក់ជាតិមួយ ដើម្បីផ្តល់តាមពេលវេលាទៀងទាត់មួយនូវ សង្ខេបព័ត៌មាន ស្តីពីរបៀបដោះស្រាយ និងគោរពតាមវិធានការការពារនានាក្នុងពេលអនុវត្តគម្រោង រេដ+។ ការវាយតម្លៃនេះបង្ហាញនូវបទពិសោធន៍ជាក់ស្តែងជាច្រើនដែលគួរដាក់បញ្ចូលទៅក្នុង ការរចនារៀបចំប្រព័ន្ធព័ត៌មានស្តីពី វិធានការធានាសុវត្ថិភាពថ្នាក់ជាតិដែលលេខាធិការដ្ឋាន រេដ+កម្ពុជា កំពុងបង្កើតឡើង (2015)។

ទី១ ជាការសំខាន់ត្រូវធានានូវសិទ្ធិកាន់កាប់ដីកសិកម្មមានស្រាប់ និងដីព្រៃ តាមទម្លាប់ពីមុនរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ ព្រៃសហគមន៍ និងការចុះបញ្ជីដីធ្លី ជាមធ្យោបាយជាក់ស្តែង សម្រាប់ដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ ព្រោះពួកវាមិនសូវទាមទារពេលវេលា និងធនធានច្រើន។ អ្នកអនុវត្ត រេដ+ អាចត្រូវពិនិត្យពីកសិកម្មពនេចរ ដើម្បីកំណត់ថា តើវាធ្វើឲ្យខូចខាតប្រព័ន្ធអេកូឡូស៊ីមែន ឬយ៉ាងណា។ ប្រសិនបើដូច្នោះមែន ចាំបាច់ត្រូវស្វែងរក និងអនុវត្តសាកល្បងនូវជម្រើសផ្សេងទៀត ដើម្បីជំនួសកសិកម្មពនេចរ។

ទី២ ពិតមែនតែFPICជាឧបករណ៍សំខាន់មួយសម្រាប់ធានាថា អ្នកចូលរួមមានសេរីភាព និងព័ត៌មានគ្រប់គ្រាន់ក្នុងការយល់ព្រមចូលរួម នៅមុនពេលអនុវត្តសកម្មភាពគម្រោងនោះ ប៉ុន្តែអ្នកអនុវត្ត FPIC ត្រូវធានាដាច់ខាតថា ខ្លួនបានផ្តល់ព័ត៌មានពេញលេញ និងមិនមែនដោយជ្រើសរើសទៅឲ្យសហគមន៍ នៅមុនពេលស្នើសុំការយល់ព្រមចូលរួមពីពួកគេ។ មិនគួរសង្កត់ធ្ងន់ហួសពេកទៅលើឱកាសល្អដែលអាចកើតចេញពីគម្រោង រេដ+ ហើយក៏មិនគួរប្រាប់ដោយសម្រាលខ្លាំងពេកដែរពី ហានិភ័យអាចកើតមានឡើង។ ករណីនៅសីមាបង្ហាញថា ការយល់ដឹងជាទូទៅអំពីគម្រោង រេដ+ និងសកម្មភាពគម្រោង ហាក់នៅមានកម្រិតទាប។ ក្នុងករណីទាំងពីរនេះ អ្នកភូមិត្រូវការព័ត៌មានបន្ថែមអំពីទំហំនៃសកម្មភាព រេដ+ ជាពិសេសខ្លឹមសារនៃកិច្ចព្រមព្រៀងដែលពួកគេបានផ្តល់ការយល់ព្រម។ ការធ្វើដូច្នេះ គឺដើម្បីធានាថា អ្នកភូមិបានយល់ដឹងពេញលេញពីអត្ថប្រយោជន៍ និងហានិភ័យអាចកើតចេញពីគម្រោងរេដ+។ ជាការសំខាន់ដែរ ត្រូវគិតគូរពីកម្រិតនៃការយល់ដឹង និងបរិបទសង្គមរបស់អ្នកពាក់ព័ន្ធនានាដែលចូលរួមក្នុងដំណើរការពិគ្រោះយោបល់ ដើម្បីធានាឲ្យមានការចូលរួមយ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាពពីសំណាក់ពួកគេ។

ទី៣ អ្នកទ្រទ្រង់គម្រោង រេដ+ ត្រូវធានាថា ភាគីពាក់ព័ន្ធទាំងអស់គោរពតាមយន្តការដោះស្រាយជំទាស់ ហើយតាមនេះ បញ្ហានានាដែលកើតចេញពីការអនុវត្តគម្រោង ឬសកម្មភាពរបស់តួអង្គពីខាងក្រៅ គឺអាចដោះស្រាយបានដោយសមស្រប។ អប្រសិទ្ធភាពក្នុងការដោះស្រាយការជំទាស់តវ៉ា វាធ្វើឲ្យសហគមន៍នៅក្នុងគម្រោងសាកល្បងទាំងពីរ មានមន្ទិលសង្ស័យលើប្រសិទ្ធភាពនៃគម្រោងរេដ+។

ទី៤ គ្រោះថ្នាក់នៃការប្រែប្រួលបញ្ច្រាស និងការកែប្រែដីព្រៃធម្មជាតិដោយសារសម្ពាធពីខាងក្រៅ រួមទាំង ការកាប់ឈើខុសច្បាប់ដោយតួអង្គនៅខាងក្នុង និងមកពីក្រៅតំបន់គម្រោង គឺនៅ

មាននៅឡើយ។ លទ្ធផលនៃការសិក្សានេះ មានផលពាក់ព័ន្ធចម្បងៗពីរ។ ទី១ ការសិក្សាផ្ដល់គំនិតថា អ្នកទ្រទ្រង់គម្រោងគួរវាយតម្លៃឡើងវិញពី កត្តាជំរុញការរេចរឹល និងបាត់បង់ព្រៃឈើដែលពួកគេកំពុងព្យាយាមដោះស្រាយ។ ទី២ ដើម្បីឲ្យគម្រោងរេដ+ ទទួលបានជោគជ័យ ត្រូវធានាថា បទបញ្ញត្តិ និងច្បាប់ទប់ស្កាត់ការកាប់ឈើខុសច្បាប់ ត្រូវបានពង្រឹងអនុវត្តន៍ជាបន្ទាន់។ កិច្ចការនេះទាមទារនូវ កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពពីសំណាក់វិស័យសំខាន់ៗដទៃទៀត ដូចជា វិស័យថាមពល កសិកម្ម និងពាណិជ្ជកម្ម ព្រមទាំងការបង្កើតចំណងតភ្ជាប់ជាមួយសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចផ្អែកលើដីធ្លីផ្សេងៗទៀត។

## ឯកសារយោង


Angelsen, Arild. 2010. "Policies for Reduced Deforestation and their Impact on Agricultural Production." *Proceedings of the National Academy of Sciences of the United States of America* 107(46): 19639-19644.

CCBS (Climate, Community and Biodiversity Alliance). 2016. "Reduced Emissions from Deforestation and Degradation in Seima Protection Forest." www.climate-standards.org/ 2013/09/12/reduced-emissions-from-deforestation-and-degradation-in-seima-protection-forest-2/.

FA & WCS. 2011. *Overview of the Seima Protection Forest REDD Project*. Phnom Penh: Forestry Administration and Wildlife Conservation Society Cambodia Program.

Nguon Pheakkdey. 2014. *REDD+ Feasibility Assessment for Community Protected Areas in Cambodia*. Phnom Penh: Ministry of Environment, Adaptation Fund and United Nations Environment Programme.

Nguon Pheakkdey and  Chhun Delux. 2015. *Background Document of Cambodia's National REDD+ Strategy*. Phnom Penh: REDD+ Taskforce Secretariat.

Nguon Pheakkdey and Dominik Kulakowski. 2013. "Natural Forest Disturbances and the Design of REDD+ Initiative." *Environmental Science and Policy* 33(4): 332-345.

Peskett, Leo, and Kimberly Todd. 2013. "Putting REDD+ Safeguards and Safeguard Information Systems Into Practice." UN-REDD Programme Policy Brief 03. Geneva: UN-REDD Programme Secretariat.

Roe, Stephanie, Charlotte Streck, Luke Pritchard and John Costenbader. 2013. *Safeguards in REDD+ and Forest Carbon Standards: A Review of Social, Environmental and Procedural Concepts and Application*. Washington, DC: Climate Focus.

RTS (REDD Taskforce Secretariat). 2015. *National REDD+ Strategy's Work Plan*. Phnom Penh: Cambodia REDD+ Tasforce Secretariat

UNFCCC (United Nations Framework Convention on Climate Change). 2013. *Report of the Conference of the Parties on its Nineteenth Session*. Warsaw, Poland: UNFCCC.

UNFCCC. 2014. "Glossary of Climate Change Acronyms." http://unfccc.int/essential_background/glossary/items/3666.php#R.

UN-REDD Programme. 2015. "Journal 7: REDD+ Safeguards and Safeguard Information Systems." *REDD+ Academy  Learning Journal*.


*តពីទំព័រ ៥* **វិទ្យាល័យនៅកម្ពុជា...**

តទៅ៖ តើគួរអនុវត្តវិធានការគោលនយោបាយអ្វីខ្លះដើម្បីបង្កើនគុណភាពអប់រំថ្នាក់មធ្យមសិក្សា? និង តើកត្តាសង្គមអ្វីខ្លះដែលជះឥទ្ធិពលលើការសិក្សារបស់សិស្ស និងការអនុវត្តរបស់គ្រូនៅក្នុងថ្នាក់រៀន?

ទោះបីមានការប្រឹងប្រែងច្រើនហើយក្ដី ក៏កំណែទម្រង់កម្មវិធីសិក្សាមិនទាន់បានប្រណិតទេ ហើយភាពមិនស៊ីគ្នារវាងការសិក្សារបស់សិស្ស និងជំនាញដែលនិយោជកត្រូវការ នៅតែជាកង្វល់ដ៏ធំ។ ការអង្កេតបន្ថែម គួរផ្ដោតលើសំណួរស្រាវជ្រាវដូចតទៅ៖ តើមានជម្រើសគោលនយោបាយអ្វីខ្លះ សម្រាប់បន្តការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីឲ្យវានៅតែសមស្របតាមតម្រូវការ? តើកម្ពុជាអាចរក្សាតុល្យភាពបានល្អប៉ុណ្ណា រវាងការធ្វើស្តង់ដានីយកម្ម និងការកែសម្រួលតាមករណីនីមួយៗ (Customization) នៃការអភិវឌ្ឍកម្មវិធីសិក្សា? តើដំណើរការដាក់បញ្ចូល ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ទៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ ឈានដល់ដំណាក់កាលណាទៅហើយ? តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលលើការដាក់បញ្ចូល TVET ទៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ? តើការដាក់បញ្ចូលវិធីសាស្ត្របង្រៀនមានអន្តរកម្មច្រើន វាមានវិសាលភាពប៉ុណ្ណា? តើធ្វើយ៉ាងណាដើម្បីផ្សារភ្ជាប់ការបង្រៀនតាមបែបបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ទៅនឹងវគ្គសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត ឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត? និង តើគ្រូបង្រៀនកម្ពុជា ត្រូវកសាងសមត្ថភាពឲ្យបានដល់កម្រិតណាដើម្បីអាចអនុវត្តវិធីសាស្ត្របង្រៀនមានអន្តរកម្មនេះបាន?

ដើម្បីអាចយល់កាន់តែច្បាស់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការបង្រៀននិងរៀនគួរ ការស្រាវជ្រាវទៅអនាគតគួរផ្ដោតលើសំណួរ ដូចជា៖ តើផលប៉ះពាល់ជាក់ស្ដែងនៃការបង្រៀនឯកជនទៅលើគុណភាពនៃការបង្រៀន កម្មវិធីសិក្សា លទ្ធផលសិក្សា និងសមភាពក្នុងការអប់រំ មានអ្វីខ្លះ? និង តើការបង្រៀនគួរនៅកម្ពុជានាពេលបច្ចុប្បន្ន មានស្ថានភាព និងនិន្នាការយ៉ាងដូចម្តេច? ប្រធានបទស្រាវជ្រាវក្នុងផ្នែកនេះ រួមមាន ១) វិសមភាពនៃការអប់រំបង្កឡើងដោយការបង្រៀនឯកជន ២) ការយល់ឃើញរបស់សិស្ស ឪពុកម្ដាយ និងគ្រូបង្រៀន លើការបង្រៀនគួរ និង ៣) តម្លៃនៃការបង្រៀនគួរ។ ការស្រាវជ្រាវទៅអនាគតស្តីពីការបង្រៀនឯកជន ក៏ត្រូវយកចិត្តទុកដាក់លើភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ និងវប្បធម៌ផ្សេងៗដែរ (Bray 2010)។

កម្មវិធីសុខភាពរបស់សាលា សំខាន់ខ្លាំងណាស់សម្រាប់ធានាឲ្យបាននូវជោគជ័យនៃការសិក្សា ក៏ដូចជា សុខភាពផ្នែករាងកាយ ផ្លូវចិត្ត បញ្ញា និងសង្គមរបស់សិស្ស។ ការសិក្សាមួយចំនួនតូចដែលបានធ្វើឡើងកន្លងមក មានទំហំតូច ហើយផ្ដោតតែលើតំបន់ទីក្រុងប៉ុណ្ណោះ។ ដូច្នេះការស្រាវជ្រាវទៅអនាគតលើបញ្ហាសុខភាពក្នុងវិស័យអប់រំ គួរពង្រីកទៅដល់តំបន់ជនបទ ហើយការស្រាវជ្រាវដើម្បីធ្វើសកម្មភាព អាចនឹងផ្ដល់នូវករណីសិក្សាដ៏មានប្រយោជន៍ជាច្រើនបន្ថែមទៀត។

សរុបមក ការស្រាវជ្រាវ គួរធ្វើឡើងឲ្យបានទៀងទាត់ដើម្បីផ្តល់ភស្តុតាង ដែលអាចរួមចំណែកដល់ការកសាងសមត្ថភាពធនធានមនុស្ស តាមរយៈកម្មវិធីសិក្សាដែលមានប្រសិទ្ធភាព គ្រូបង្រៀនដែលមានសមត្ថភាព និងកម្មវិធីអប់រំដែលសមស្របតាមតម្រូវការ។ ថវិកាជាតិ ក៏គួរមានចែកសម្រាប់ជួយទ្រទ្រង់ដល់ការសិក្សាស្រាវជ្រាវផ្នែកអប់រំ ជាពិសេស ការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិដែរ។

## ឯកសារយោងមាននៅក្នុងអត្ថបទជាភាសាអង់គ្លេស

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាអំពីសូចនាករសេដ្ឋកិច្ចនៅប្រទេសធំៗមួយចំនួន និងនៅអាស៊ីអាគ្នេយ៍។

នៅត្រីមាសទី១ ឆ្នាំ២០១៦ ផសស ពិត នៅឥណ្ឌូនេស៊ីកើន ៤,៩% ធៀបនឹង ៥,០% កាលពីត្រីមាសទី៤ ឆ្នាំ២០១៥។ ក្នុងត្រីមាសនេះដែរ ឥណ្ឌូនេស៊ី អាចធ្វើឲ្យអតិផរណារបស់ខ្លួនមានលំនឹង និងកែប្រែនយោបាយរូបិយវត្ថុ ដោយកាត់បន្ថយអត្រាការប្រាក់មកត្រឹម ៦,៥%។ កំណើនប្រចាំឆ្នាំនៅម៉ាឡេស៊ី ធ្លាក់ចុះមកត្រឹម ៤,២% ធៀបនឹង ៤,៥% ក្នុងត្រីមាសមុន ក្នុងនេះតម្រូវការក្នុងស្រុកដែលតំណាងឲ្យ ៨៥% នៃកំណើនសេដ្ឋកិច្ចសរុប គឺជាកត្តាជំរុញចម្បង។ សេដ្ឋកិច្ចសិង្ហបុរីកើន ១,៨% គឺប៉ុនគ្នានឹងត្រីមាសមុន។ សេដ្ឋកិច្ចថៃមានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៣,២% ធៀបនឹង ២,៨% ក្នុងត្រីមាសមុន រីឯវៀតណាមមានអត្រាកំណើន ៥,៥% គឺទាបជាងអត្រា ៧,០% កាលពីត្រីមាសមុនដោយសារចំណូលបានពីប្រេងឆៅនិងកសិកម្មបានរួមចុះ។

ចិនមានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៦,៧% ហើយឧស្សាហកម្មបានរួមចំណែកយ៉ាងសំខាន់ នៅក្នុងត្រីមាសទី១នេះ។ សេដ្ឋកិច្ចហុងកុងមានអត្រាកំណើន ០,៨% គឺទាបជាងអត្រាកំណើនរំពឹងទុកពី ១,០% ទៅ ២,០% និងទាបជាងកាលពីត្រីមាសមុន ដែលមានអត្រាកំណើន ១,៩% ដោយសារការធ្លាក់ចុះសកម្មភាពលក់ទំនិញរាយ និងការចុះថ្លៃអចលនទ្រព្យ។ នៅត្រីមាសទី១ កំណើននៅកូរ៉េខាងត្បូង មានត្រឹម ២,៧% ដែលទាបជាងការរំពឹងទុក និងទាបជាងកាលពីត្រីមាសមុន ដែលមានដល់ ៣,០% ។ កំណើន ផសស គិតក្នុងមួយឆ្នាំនៅតៃវ៉ាន់ រួមចុះ ០,៨% ដោយសារការនាំចេញមានកម្រិតទាប។ ការនាំចូលក៏រួមចុះដែរ ប៉ុន្តែចុះតិចជាងការនាំចេញ។

ក្នុងត្រីមាសទី១ កំណើន ផសស ពិតក្នុងតំបន់ អឺរ៉ូ ១២ នៅថេរ ត្រឹម ១,៥% គិតក្នុងមួយឆ្នាំ។ សេដ្ឋកិច្ចជប៉ុនមានកំណើន ០,២% ក្នុងត្រីមាសទី១ នេះ។ ចំណាយប្រើប្រាស់ក្នុងស្រុកនៅជប៉ុនកើនឡើង ប៉ុន្តែការនាំចេញជួបការលំបាក ដោយសារប្រាក់យ៉េនឡើងថ្លៃ។ អត្រាកំណើនប្រចាំឆ្នាំនៅសហរដ្ឋអាមេរិកកើនឡើង ២,១% ដោយសារការកែលំអវិនិយោគផ្នែកពាណិជ្ជកម្ម និងជំនួញ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

អត្រាអតិផរណាក្នុងប្រទេសអាស៊ី និងអាស៊ានខ្លះ បានកើនឡើង ប៉ុន្តែក្នុងប្រទេសខ្លះទៀតនៅតែមានបរិត្តផរណា។ នៅកម្ពុជា អតិផរណាមានកម្រិត ២,៤% ហើយនៅឥណ្ឌូនេស៊ីមានដល់ ៤,៣%។ នៅសិង្ហបុរី មានបរិត្តផរណា ០,៨% ធៀបនឹងបរិត្តផរណា ០,៧% ក្នុងត្រីមាសទី៤ ឆ្នាំ២០១៥។ សិង្ហបុរីមានអតិផរណាអវិជ្ជមានក្នុង ៥ត្រីមាសជាប់ៗគ្នា។ ថៃមានបរិត្តផរណា ០,៥% ធៀបនឹងបរិត្តផរណា ០,៩% កាលពីត្រីមាសមុន។ ការថយចុះភាពគ្មានការងារធ្វើ កំណើនការនាំចេញមាសចំណូលយ៉ាងខ្ពស់ផ្នែកទេសចរណ៍ និងការថយចុះការនាំចូលទំនិញ បានរួមចំណែកដល់ការធ្លាក់ចុះបរិត្តផរណា។ អតិផរណានៅវៀតណាម មានអត្រា ១,៣% ដោយសារថ្លៃប្រេងក្នុងពិភពលោកកើនឡើង និងការផ្គត់ផ្គង់អាហារក្នុងទីផ្សារធ្លាក់ចុះ។

អតិផរណានៅចិន មានអត្រា ២,១% គឺខ្ពស់ជាងកាលពីត្រីមាសមុន។ ថ្លៃអាហាររួមចំណែក ២៥% ក្នុង កំណើន CPI នៅចិន។ ហុងកុងមានអត្រាអតិផរណា ២,៩% កូរ៉េខាងត្បូងមានអត្រា ០,២% តៃវ៉ាន់មានអត្រា ១,៧% តំបន់អឺរ៉ូមានអត្រា ០,១% ជប៉ុនមានអត្រា ០,២% និងសហរដ្ឋអាមេរិក មានអត្រា ១,១%។

នៅត្រីមាសទី១ ឆ្នាំ២០១៦ ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលធ្លាក់ថ្លៃ ០,៨% ធៀបនឹងត្រីមាសមុន និង ០.៣% ធៀបនឹងឆ្នាំមុនមកត្រឹម ៤០៥៦,៣រៀល/ដុល្លារ។ ប្រាក់បាតថៃឡើងថ្លៃ ១,១% ធៀបនឹងត្រីមាសមុន ប្រាក់ដុងវៀតណាមឡើងថ្លៃ ២,៧% ប្រាក់យ៉ន់ចិន ឡើងថ្លៃ ០,១៦% ហើយ ប្រាក់យ៉េនជប៉ុនឡើងថ្លៃ ៦,៤%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ ថ្លៃទំនិញសំខាន់ៗនៅលើទីផ្សារពិភពលោក បានធ្លាក់ចុះ ធៀបនឹងត្រីមាសមុន។ ពោតធ្លាក់ថ្លៃ ៨,២% មកត្រឹម ១៦០,០ដុល្លារ/តោន ប្រេងដូងប្រេងធ្លាក់ថ្លៃ ៦,៥% មកត្រឹម ៥៨៦,៩ដុល្លារ/តោន ហើយ កៅស៊ូធ្លាក់ថ្លៃ ១៧,៩% មកត្រឹម ១១៩០,០ដុល្លារ/តោន។ អង្ករធ្លាក់ថ្លៃ ៩,៥% មកត្រឹម ៣៨៥,៣ដុល្លារ/តោន ហើយ សណ្តែកសៀងធ្លាក់ថ្លៃ ២៤,១% មកត្រឹម ៣២៨,០ដុល្លារ/តោន។ ប្រេងឆៅ ធ្លាក់ថ្លៃ ៣៨,៧% មកត្រឹម ៣១,២ដុល្លារ/ធុង បណ្តាលឲ្យ សាំងធ្លាក់ថ្លៃ ៣០,៣% និង ម៉ាសូតធ្លាក់ថ្លៃ ៣៩,១%។

---

អត្ថបទនេះ រៀបរាងដោយលោកស្រី ស្រី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 6.7 | 0.1 | 6.0 | 7.1 | 7.3 | 7.4 | | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 4.7 | 4.7 | 4.7 | 5.0 | 4.9 |
| ម៉ាឡេស៊ី | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.6 | 6.0 | 5.6 | 4.9 | 4.7 | 4.5 | 4.2 |
| សិង្ហបុរី | 1.1 | -4.5 | 14.7 | 4.7 | 1.3 | 3.8 | 3.0 | 2.6 | 1.8 | 1.9 | 1.8 | 1.8 |
| ថៃ | 2.6 | 3.3 | 7.9 | 0.0 | 6.7 | 2.8 | 1.6 | 3.3 | 2.2 | 2.9 | 2.8 | 3.2 |
| វៀតណាម | 5.7 | 5.4 | 6.4 | 6.2 | 5.2 | 5.4 | 5.9 | 6.1 | 6.5 | 6.8 | 7.0 | 5.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.0 | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.3 | 7.1 | 7.0 | 6.9 | 6.8 | 6.7 |
| ហុងកុង | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 3.0 | 2.3 | 2.1 | 2.8 | 2.3 | 1.9 | 0.8 |
| កូរ៉េខាងត្បូង | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 2.8 | 3.4 | 2.4 | 2.2 | 2.7 | 3.0 | 2.7 |
| តៃវ៉ាន់ | 0.1 | -3.6 | 11.1 | 4.2 | 1.2 | 2.2 | 3.5 | 3.4 | 0.5 | -1.0 | -0.5 | -0.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 0.1 | 0.7 | 1.0 | 1.2 | 1.6 | 1.5 | 1.5 |
| ជប៉ុន | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 1.7 | 0.6 | -0.9 | 0.7 | 1.0 | 0.5 | 0.2 |
| សហរដ្ឋអាមេរិក | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 2.4 | 2.7 | 2.3 | 2.2 | 1.8 | 2.1 |

Sources: International Monetary Fund, Economist and countries' statistics offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៦ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 19.7 | | 4.1 | 5.5 | 3.0 | 3.0 | 3.9 | 1.0 | 1.0 | 0.8 | 2.0 | 2.4 |
| ឥណ្ឌូនេស៊ី | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 7.0 | 6.4 | 6.6 | 7.1 | 7.1 | 4.8 | 4.3 |
| ម៉ាឡេស៊ី | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 2.1 | 3.2 | 0.7 | 2.1 | 3.0 | 2.6 | 3.4 |
| សិង្ហបុរី | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 2.3 | 1.0 | -0.3 | -0.4 | -0.6 | -0.7 | -0.8 |
| ថៃ | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 2.2 | 1.9 | -0.5 | -1.1 | -1.1 | -0.9 | -0.5 |
| វៀតណាម | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 0.7 | 1.0 | 0.5 | 0.3 | 1.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.6 | 2.0 | 1.2 | 1.4 | 1.7 | 1.5 | 2.1 |
| ហុងកុង | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 4.0 | 4.4 | 4.4 | 3.1 | 2.3 | 2.4 | 2.9 |
| កូរ៉េខាងត្បូង | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.1 | 1.3 | 0.6 | 0.5 | 0.6 | 1.1 | 0.2 |
| តៃវ៉ាន់ | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 0.8 | 1.5 | 2.9 | -0.7 | 0.0 | 0.3 | 1.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.4 | 0.4 | -0.3 | 0.2 | 0.0 | 0.3 | 0.1 |
| ជប៉ុន | 1.4 | -1.3 | -0.7 | 0.1 | -0.03 | 0.4 | 2.8 | 2.3 | 0.5 | 0.2 | 0.7 | 0.2 |
| សហរដ្ឋអាមេរិក | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.5 | 1.6 | -0.4 | 0.0 | 0.1 | 0.4 | 1.1 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4054.2 | 4140.48 | 4187.1 | 4063.6 | 4037.8 | 4027.2 | 4037.6 | 4042.2 | 4056.7 | 4091.8 | 4022.4 | 4056.3 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9699 | 10413.83 | 9089.9 | 8748.0 | 9363.0 | 10419.2 | 11850.2 | 12809.9 | 13125.2 | 13858.0 | 13627.3 | 13324.1 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.52 | 3.2 | 3.1 | 3.1 | 3.1 | 3.3 | 3.6 | 3.7 | 4.1 | 4.2 | 4.0 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.42 | 1.45 | 1.4 | 1.3 | 1.2 | 1.3 | 1.3 | 1.4 | 1.3 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 33.36 | 34.34 | 31.7 | 30.5 | 31.1 | 30.7 | 32.5 | 32.6 | 33.2 | 35.2 | 35.6 | 35.3 |
| វៀតណាម (ដុង) | 16382 | 17725.24 | 19200.8 | 20574.3 | 20856.9 | 20990.3 | 21138.2 | 21372.9 | 21712.7 | 22164.6 | 22929.4 | 22314.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.94 | 6.83 | 6.8 | 6.5 | 6.3 | 6.1 | 6.2 | 6.2 | 6.2 | 6.3 | 6.4 | 6.5 |
| ហុងកុង (ដុល្លារហុងកុង) | 7.78 | 7.75 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1137.23 | 1277.76 | 1156.3 | 1108.6 | 1126.6 | 1095.0 | 1053.6 | 1101.7 | 1097.4 | 1170.0 | 1200.8 | 1163.4 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.54 | 33.04 | 31.5 | 29.4 | 29.6 | 29.7 | 30.3 | 31.6 | 30.8 | 32.0 | 33.1 | 32.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.84 | 0.72 | 0.8 | 0.7 | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 102.46 | 93.6 | 87.8 | 79.9 | 79.8 | 97.6 | 105.9 | 119.2 | 121.4 | 122.2 | 115.3 | 107.9 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៨-២០១៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No.2) - USA (USD/តោន) | 218.2 | 167.3 | 185.9 | 291.7 | 298.4 | 259.4 | 192.9 | 174.2 | 168.4 | 169.5 | 167.1 | 160.0 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (USD/តោន) | 912.2 | 686.8 | 900.8 | 1125.4 | 999.3 | 856.9 | 821.4 | 627.9 | 664.0 | 514.6 | 518.0 | 586.9 |
| កៅស៊ូ SMR 5 USD/តោន) | 2586.3 | 1884.8 | 3405.7 | 4630.6 | 3200.7 | 2575.3 | 1755.6 | 1450.2 | 1525.9 | 1365.5 | 1229.1 | 1190.0 |
| អង្ករ (Thai 100% B) - បាងកក (USD/តោន) | 615.3 | 524.5 | 506.6 | 558.5 | 594.8 | 533.8 | 434.9 | 426.0 | 396.3 | 383.3 | 376.3 | 385.3 |
| សណ្ដែកសៀង (US No.1) - USA (USD/តោន) | 460.4 | 414.0 | 449.8 | 540.7 | 591.4 | 538.4 | 491.8 | 363.9 | 393.7 | 347.6 | 358.0 | 328.0 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 95.4 | 60.5 | 76.8 | 106.2 | 109.5 | 105.9 | 96.2 | 50.9 | 60.5 | 48.2 | 38.0 | 31.2 |
| សាំង - US Gulf Coast (សេន/លីត្រ) | 62.2 | 42.9 | 53.3 | 71.9 | 74.6 | 71.2 | 65.6 | 40.1 | 49.0 | 42.2 | 32.9 | 27.9 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 76.2 | 43.1 | 56.1 | 75.7 | 80.7 | 78.4 | 71.5 | 44.6 | 48.4 | 39.9 | 34.0 | 27.2 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ឆ្នាំ២០១៦ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ កើន ៨០,៥% ធៀបនឹងត្រីមាសមុន ដល់ ៩២៣,៧លានដុល្លារ ប៉ុន្តែធ្លាក់ចុះ ៦៧,៩% ធៀបនឹងមួយឆ្នាំមុន។ វិនិយោគក្នុងវិស័យកសិកម្ម កើន ៦,៨% ដល់ ២៧,៦លានដុល្លារ។ អនុមតិវិនិយោគក្នុងអនុវិស័យកាត់ដេរ កើន ២៨,១% ធៀបនឹងត្រីមាសមុនដល់ ៥៥,២លានដុល្លារ។ អនុមតិវិនិយោគសម្រាប់អនុវិស័យសណ្ឋាគារ និងទេសចរណ៍ កើន ១៥០៨% ដល់ ៦១១,១លានដុល្លារ ធៀបនឹង ៣៨,០លានដុល្លារកាលពីត្រីមាសមុន។

នៅត្រីមាសទី១ នេះដែរ ចំនួនភ្ញៀវបរទេសមកដល់សរុប រួមចុះ ៦,០% ធៀបនឹងត្រីមាសមុន និង ២,២% ធៀបនឹងត្រីមាសទី១ ឆ្នាំមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើនឡើង ១៥,២% រីឯភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក ធ្លាក់ចុះ ២៥,៤% ធៀបនឹងត្រីមាសមុន។

នៅត្រីមាសទី១ ឆ្នាំ២០១៦ ការនាំចេញសរុប កើន ៣,៤% ធៀបនឹងត្រីមាសមុន និង ១០,១% ធៀបនឹងមួយឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ កើន ៤,៧% ដល់ ១៧៥៩,៤លានដុល្លារ ធៀបនឹង ១៦៨១,២លានដុល្លារ កាលពីត្រីមាសមុន។ ការនាំចេញទៅសហរដ្ឋអាមេរិក ធ្លាក់ចុះ ៣,៦% ធៀបនឹងត្រីមាសមុន និង ១៣,៩% ធៀបនឹងឆ្នាំមុន។ ការនាំចេញទៅសហភាពអឺរ៉ុប កើន ៤,៤% ធៀបនឹងត្រីមាសមុន ដល់ ៧៨៩,៦លានដុល្លារ រីឯការនាំចេញទៅបណ្ដាប្រទេសអាស៊ាន ធ្លាក់ចុះ ៧,១% មកត្រឹម ២៥,៦លានដុល្លារ។ ការនាំចេញផលិតផលកសិកម្ម រួមចុះ ១៣,៩% ធៀបនឹងត្រីមាសមុន ក្នុងនោះការនាំចេញកៅស៊ូ ធ្លាក់ចុះ ២៤,៥% ឈើ ៦៧,៩% និង អង្ករ ៧,៥%។

នៅត្រីមាសទី១ ដដែលនេះ ការនាំចូល ធ្លាក់ចុះ ៥,៦% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ២,៥% ធៀបនឹងឆ្នាំមុន ដល់ ២៧៨៤,៧លានដុល្លារ។ ការនាំចូល សាំងកើន ៤៦,៦% ម៉ាស៊ូតកើន ៨,៨% និងសម្ភារសំណង់កើន ២០,៦% ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០១៦ ចំណូលរដ្ឋាភិបាលសរុប កើន ២៣,២% ធៀបនឹងត្រីមាសមុន ដល់ ៣៥៣២,៨ប៊ីលានរៀល ក្នុងនោះ ចំណូលចរន្ត កើន ២៤,៧% ដល់ ៣៥១៤,៦ប៊ីលានរៀល។ ចំណូលពន្ធ កើន ៣៥,១% ដល់ ៣២៥៥,៥ប៊ីលានរៀល រីឯចំណូលមិនមែនពន្ធ ធ្លាក់ចុះ ៣៦,៦% មកត្រឹម ២៥៩,១ប៊ីលានរៀល។ នៅត្រីមាសដដែលនេះ ចំណាយសរុប ធ្លាក់ចុះ ៥៣,៨% ធៀបនឹងត្រីមាសមុន មកត្រឹម ២៣៦៧,៩ប៊ីលានរៀល ដោយសារការធ្លាក់ចុះ ៧០,០% (៦២៤,៥ប៊ីលានរៀល) នៃចំណាយមូលធន និង ៤២,៦% (១៧៤៣,៤ប៊ីលានរៀល) នៃចំណាយចរន្ត។

---

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០១៦ សន្ទស្សន៍ថ្លៃទំនិញសរុប កើន ២,៥%។ ថ្លៃអាហារ និងភេសជ្ជៈមិនមែនស្រា កើន ៤,៧% ប៉ុន្តែថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ៦,៥%។ ប្រាក់រៀល ឡើងថ្លៃ ០,៧% ទល់នឹងប្រាក់ដុល្លារ និង ០,២% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែធ្លាក់ថ្លៃ ០,៥% ទល់នឹងប្រាក់ដុងវៀតណាម ធៀបនឹងត្រីមាសមុន។ ម៉ាស៊ូតធ្លាក់ថ្លៃ ១៤,៣% ហើយសាំងធ្លាក់ថ្លៃ ៧,៦%។

## ស្ថានភាពក្រីក្រ

នៅខែឧសភា ២០១៦ ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នករត់ស៊ីក្លូ អ្នកលក់បន្លែតូចតាច អ្នកស៊ីឈ្នួលធ្វើស្រែ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់ កើនឡើង បើធៀបនឹងខែដូចគ្នា ឆ្នាំមុន រីឯចំណូលប្រចាំថ្ងៃពិតរបស់អ្នកលីសែង អ្នករើសអេតចាយ អ្នករត់តុភោជនីយដ្ឋាន និងកម្មករកាត់ដេរ ធ្លាក់ចុះ។

ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ៤,៨% ធៀបនឹងខែឧសភា ឆ្នាំមុន ដល់ ៧៩១៦រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ប្រហែល ៤៥% ជាប្រភពចំណូលចម្បងសម្រាប់គ្រួសារខ្លួន ហើយ ៦៧% ប្រាប់ថា គាត់រកចំណូលបានតិចជាងត្រីមាសមុន។ ពលករភាគច្រើនបញ្ជាក់ថា ចំណូលរបស់គាត់ក្នុងខែឧសភា អាចទ្រទ្រង់ជីវភាពគ្រួសារបាន។ ពលករ ៥០% មានជាប់បំណុលគេ ហើយអត្រាការប្រាក់ជាមធ្យមលើការខ្ចីបុលនោះ គឺប្រហែល ៣% ក្នុងមួយខែ។

ប្រាក់កម្រៃប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើន ៦,៣% ដល់ ១៣.៨២៨រៀល។ កម្មករ ៦០% រៀបការរួច។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ ទទួលបានការអប់រំត្រឹមកម្រិតបឋមសិក្សា។ ជាមធ្យម ពួកគេធ្វើការឲ្យរោងចក្របាន ៤,៥ឆ្នាំហើយ។ ពួកគេភាគច្រើនទទួលបានជំនាញមុនពេលចូលធ្វើការរោងចក្រ តាមរយៈការបណ្ដុះបណ្ដាលជាលក្ខណៈឯកជន រីឯអ្នកផ្សេងទៀតទទួលបានជំនាញ តាមរយៈការបណ្ដុះបណ្ដាលក្នុងកន្លែងធ្វើការនៅឯរោងចក្រ។ ជាមធ្យម ពួកគេធ្វើការ ៥៣ម៉ោង/សប្ដាហ៍ និងសន្សំប្រាក់បានដល់៦២%នៃប្រាក់កម្រៃរបស់ខ្លួន។ ប្រាក់សន្សំភាគច្រើនពួកគេផ្ញើទៅផ្ទះ ហើយវាអាចជួយទ្រទ្រង់ជីវភាពគ្រួសារបាន។ កម្មករ ៤៨% មិនចង់ផ្លាស់ប្ដូរការងារទេ ហើយ ៨១% មានសុទិដ្ឋិនិយមថា រោងចក្រគាត់នៅតែមានដំណើរការតទៅអនាគតទៀត។

ចំណូលរបស់អ្នកលក់បន្លែតូចតាច កើន ១១,៥% ធៀបនឹងអង្កេតលើកមុន ដល់ ១៨.៩៧៩រៀល/ថ្ងៃ។ អ្នកលក់បន្លែភាគច្រើនជាអ្នកមកពីខេត្តក្រុងផ្សេងទៀត ដូចជា កណ្ដាល (៣២,៥%) ស្វាយរៀង (១៥%) ព្រៃវែង (១២,៥%) ភ្នំពេញ (១០%) សៀមរាប (១០%) តាកែវ (១០%) កំពង់ស្ពឺ (៧,៥%) និងកំពង់ចាម (២,៥%)។ ពួកគេ ៧៨% មានដីកសិកម្មពី ១ ទៅ ៣ហិកតា ហើយអ្នកក្រៅពីនោះ មិនមានដីទេ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយមិនមានមូលធនគ្រប់គ្រាន់សម្រាប់បម្រើអាជីវកម្មរបស់ខ្លួនទេ។

ចំណូលរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ៣៤,២% មកត្រឹម ៨៧៣៧រៀល/ថ្ងៃ ដោយសារកំណើនចំនួនអ្នករើសអេតចាយ នៅតំបន់ចាក់សម្រាម និងការថយចុះប្រភពសម្រាម។ ពួកគេភាគច្រើន ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយត្រូវធ្វើការប្រហែល ១០ម៉ោង/ថ្ងៃ ដើម្បីទ្រទ្រង់គ្រួសារខ្លួន។ ជាមធ្យម ពួកគេចាយអស់ ៥៣,៣% នៃចំណូល ហើយភាគច្រើនទៅលើថ្លៃអាហារ (៨៤,២%) ថ្លៃឈ្នួលកន្លែងស្នាក់នៅ (១២,៥%) និងមួយភាគតូចណាស់លើថ្លៃថែទាំសុខភាព និងការចំណាយផ្សេងទៀត។

នៅខែឧសភា ចំនួនកម្មករសំណង់គ្មានជំនាញបានកើនឡើង ប៉ុន្តែសកម្មភាពសាងសង់ក៏កើនឡើងដែរ ដែលនាំឲ្យចំណូលប្រចាំថ្ងៃរបស់ពួកគេ កើនឡើង ៣៩,៧% ដល់ ២០.២២៧រៀល។ អ្នកឆ្លើយសម្ភាសន៍ ៦៥% ធ្វើចំណាកស្រុកមករាជធានីភ្នំពេញ ឬខេត្តសៀមរាប ដើម្បីរកការងារធ្វើ។ ជាមធ្យម ពួកគេធ្វើការ ៨,៥ ម៉ោង/ថ្ងៃ ហើយត្រូវចំណាយប្រាក់ភាគច្រើនទៅលើម្ហូបអាហារ។ ចំណូលរបស់ពួកគេ អាចទ្រទ្រង់គ្រួសារបាន។

ចំណូលរបស់អ្នកលីសែងធ្លាក់ចុះ២០,៣%មកត្រឹម១១.៨៩៨ រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាធ្វើចំណាកស្រុកមកពីខេត្ត ហើយស្នាក់នៅរួមគ្នាចំនួន ៥នាក់ជាមធ្យមក្នុងមួយបន្ទប់។ ចំណូលរបស់ពួកគេ ចាយវាយជាសំខាន់លើ ម្ហូបអាហារ (៧៦%) ថ្លៃឈ្នួលកន្លែងស្នាក់នៅ (១៧,៥%) ការថែទាំសុខភាព (០,៤%) និងមុខចំណាយផ្សេងទៀត (៦,០%)។ អ្នកឆ្លើយសម្ភាសន៍ ៥៨% ប្រាប់ថា តាំងពីចាប់ផ្ដើមធ្វើជាអ្នកលីសែងមក គ្រួសាររបស់ពួកគេមានជីវភាពប្រសើរជាងមុន ប៉ុន្តែមាន ៧,៥% ប្រាប់ថា គ្រួសារខ្លួនមានជីវភាពលំបាកជាងមុន។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់តុភោជនីយដ្ឋាន ធ្លាក់ចុះបន្តិចមកត្រឹម ៨១៨៧រៀល។ ពួកគេ ៩៣% ស្នាក់នៅក្នុងហាង។ ពួកគេធ្វើការនេះបាន ៤ឆ្នាំហើយ និងត្រូវបម្រើការក្នុងហាងជាមធ្យម ១១,៨ម៉ោង/ថ្ងៃ។ ពួកគេចំណាយ ២៥,៥% នៃចំណូលសរុបទៅលើម្ហូបអាហារ។ អ្នកឆ្លើយសម្ភាសន៍ ផ្ញើ ៦៩% នៃចំណូលរបស់ខ្លួន ទៅឲ្យគ្រួសារ ហើយប្រាក់ផ្ញើនេះអាចជួយទ្រទ្រង់ជីវភាពគ្រួសារបានតែមួយភាគប៉ុណ្ណោះ។

តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៨-១៦*

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 92.0 | 615.0 | 530.7 | 725.0 | 531.6 | 930.5 | 56.5 | 25.8 | 38.1 | 79.1 | 26.8 | 27.6 |
| ឧស្សាហកម្ម | 724.9 | 818.5 | 403.7 | 2860.1 | 829.3 | 3257.0 | 1002.5 | 342.8 | 130.9 | 130.6 | 410.4 | 252.4 |
| *កាត់ដេរ* | 142.8 | 90.1 | 122.8 | 393.9 | 497.0 | 324.1 | 393.5 | 63.9 | 42.4 | 63.7 | 55.2 | 70.8 |
| សេវាកម្ម | 10,003.2 | 4432.0 | 1337.3 | 3425.4 | 916.6 | 140.7 | 622.6 | 2504.6 | 85.6 | 69.7 | 74.5 | 643.6 |
| *សណ្ឋាគារ និងទេសចរណ៍* | 8758.1 | 3980.1 | 1105.1 | 2850.9 | 691.5 | 106.0 | 446.9 | 60.6 | 0.0 | 0.0 | 38.0 | 611.1 |
| សរុប | 10,570.9 | 5865.5 | 2271.7 | 7010.4 | 2278.0 | 4328.0 | 1583.9 | 2873.2 | 254.6 | 279.4 | 511.7 | 923.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | | 1816.8 | -91.1 | 9.7 | 83.1 | 80.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 308.6 | -45.5 | -61.3 | 209.0 | -67.5 | 90.1 | 63.4 | 573.0 | -33.2 | -55.3 | 241.4 | -67.9 |

*Including expansion project approvals. Source: Cambodian Investment Board

តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៨-១៦

| | | | | | | | | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ ( ពាន់នាក់ ) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 2017.7 | 2273.5 | 725.1 | 497.4 | 563.8 | 681.3 | 785.0 |
| តាមផ្លូវគោក និងទឹក | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 2192.5 | 2229.3 | 647.6 | 496.7 | 481.1 | 747.0 | 557.4 |
| សរុប | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 4210.2 | 4502.8 | 1372.6 | 994.2 | 1044.9 | 1428.4 | 1342.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | | 5.4 | -27.6 | 5.1 | 36.7 | -0.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 5.5 | -0.5 | 13.6 | 20.1 | 24.4 | 17.5 | 7.0 | 8.3 | 6.5 | 4.6 | 9.6 | -2.4 |

Source: Ministry of Tourism

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៨-១៦ *

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 6982.4 | 8106.0 | 2170.1 | 2182.0 | 2595.0 | 2309.3 | 2388.3 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 5386.1 | 5960.5 | 1548.8 | 1601.7 | 1995.3 | 1681.2 | 1759.4 |
| - *សហរដ្ឋអាមេរិក* | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 2075.2 | 1963.6 | 491.1 | 494.3 | 585.3 | 438.8 | 423.1 |
| - *សហភាពអឺរ៉ុប* | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 1969.6 | 2403.7 | 617.3 | 685.9 | 844.1 | 756.6 | 789.6 |
| - *អាស៊ាន* | 10.8 | 6.9 | 9.9 | 17.6 | 39.4 | 60.2 | 83.3 | 24.8 | 24.6 | 26.4 | 27.5 | 25.6 |
| - *ជប៉ុន* | 25.2 | 44.6 | 86.5 | 147.0 | 188.6 | 278.7 | 383.1 | 121.4 | 93.6 | 170.8 | 138.4 | 176.0 |
| - *ប្រទេសផ្សេងៗ* | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 1002.9 | 1126.8 | 294.2 | 303.4 | 368.8 | 319.9 | 345.2 |
| កសិកម្ម | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 554.5 | 624.4 | 150.3 | 127.3 | 111.4 | 159.7 | 137.5 |
| - *កៅស៊ូ* | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 175.2 | 153.9 | 41.7 | 40.9 | 42.1 | 40.7 | 30.7 |
| - *ឈើ* | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 73.6 | 132.0 | 13.9 | 9.8 | 7.3 | 15.3 | 4.9 |
| - *ត្រី* | 2.3 | 4.0 | 2.8 | 3.1 | 2.0 | 1.2 | 0.8 | 0.2 | 0.2 | 0.1 | 0.1 | 0.2 |
| - *អង្ករ* | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 262.3 | 248.5 | 89.5 | 72.4 | 54.7 | 98.8 | 91.4 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 42.4 | 89.1 | 5.2 | 4.0 | 7.2 | 4.9 | 10.3 |
| ផ្សេងៗ | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 1088.2 | 1520.1 | 471.0 | 452.9 | 488.0 | 468.4 | 491.3 |
| ការនាំចូលសរុប ក្នុងនេះ៖ | 4272.0 | 4332.0 | 5190.6 | 6375.9 | 8593.3 | 8639.4 | 10,295.4 | 2717.3 | 2920.3 | 2907.9 | 2949.1 | 2784.7 |
| សាំង | 84.9 | 91.1 | 108.6 | 294.4 | 308.0 | 306.4 | 334.7 | 34.5 | 92.2 | 96.5 | 65.1 | 95.4 |
| ម៉ាស៊ូត | 119.5 | 180.7 | 203.8 | 447.0 | 559.5 | 569.1 | 602.3 | 45.1 | 152.7 | 139.6 | 150.0 | 163.1 |
| សម្ភារសំណង់ | 56.3 | 49.7 | 57.6 | 48.1 | 66.1 | 80.8 | 117.6 | 12.4 | 42.0 | 45.9 | 42.1 | 50.8 |
| ផ្សេងៗ | 4011.8 | 4010.0 | 4820.6 | 5586.4 | 7659.1 | 7682.6 | 9240.7 | 835.2 | 2633.0 | 2626.0 | 2691.9 | 2475.0 |
| ជញ្ជីងពាណិជ្ជកម្ម | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | -1610.9 | -2184.3 | -547.2 | -738.3 | -312.9 | -639.7 | -396.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | - | 3.8 | 3.4 | 24.6 | -15.7 | 4.7 |
| ការនាំចេញសរុប | - | - | - | - | - | - | - | 1.5 | 0.5 | 18.9 | -11.0 | 3.4 |
| ការនាំចូលសរុប | - | - | - | - | - | - | - | -3.2 | 7.5 | -0.4 | 1.4 | -5.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 1.6 | -14.1 | 25.7 | 32.1 | 17.7 | 7.4 | 10.7 | 5.8 | 16.1 | 22.8 | 12.6 | 13.6 |
| ការនាំចេញសរុប | 1.6 | -6.3 | 25.1 | 35.8 | 23.9 | 14.3 | 16.1 | 9.8 | 17.3 | 21.7 | 8.1 | 10.1 |
| ការនាំចូលសរុប | 13.3 | 1.4 | 19.8 | 22.8 | 16.8 | 15.4 | 19.7 | 21.4 | 19.2 | 4.0 | 5.0 | 2.5 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៨-១៦ (ប៊ីលានរៀល)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 5290.0 | 5989.0 | 5989.0 | 6251.4 | 7691.9 | 8255.2 | 10,543.4 | 2647.8 | 3301.6 | 3063.8 | 2867.3 | 3532.8 |
| ចំណូលចរន្ត | 5210.7 | 5859.1 | 5859.1 | 6179.3 | 7443.8 | 8233.2 | 10,359.4 | 2638.0 | 3274.5 | 3028.7 | 2818.2 | 3514.6 |
| ចំណូលពន្ធ | 4409.9 | 4693.0 | 4693.0 | 5277.5 | 6334.8 | 7198.1 | 8995.2 | 2430.6 | 3006.1 | 2656.2 | 2409.7 | 3255.5 |
| ពន្ធក្នុងស្រុក | 3248.4 | 3533.6 | 3533.6 | 4071.6 | 5002.8 | 5728.1 | 7226.5 | 2012.6 | 2481.6 | 2153.9 | 1943.6 | 2715.4 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1161.5 | 1159.4 | 1159.4 | 1205.9 | 1331.7 | 1470.0 | 1822.7 | 418.0 | 524.5 | 502.3 | 466.1 | 540.1 |
| ចំណូលមិនមែនពន្ធ | 800.8 | 1166.1 | 1166.1 | 901.8 | 1118.2 | 1035.2 | 1310.3 | 207.4 | 268.5 | 372.5 | 408.5 | 259.1 |
| ចំណូលលើទ្រព្យសម្បត្តិ | 78.0 | 291.1 | 291.1 | 63.8 | 143.0 | 84.0 | 88.5 | 3.0 | 16.7 | 35.9 | 21.7 | 8.2 |
| លក់ទំនិញ និងសេវា | 424.7 | 460.1 | 460.1 | 588.7 | 667.4 | 750.3 | 871.2 | 189.6 | 219.2 | 304.6 | 333.9 | 198.3 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.2 | 408.9 | 408.9 | 249.3 | 298.8 | 200.8 | 350.5 | 14.8 | 32.6 | 31.8 | 53.0 | 52.7 |
| ចំណូលជាមូលធន | 79.3 | 129.9 | 129.9 | 72.1 | 247.9 | 73.4 | 184.0 | 9.8 | 27.1 | 35.0 | 49.1 | 18.3 |
| ចំណាយសរុប | 6297.8 | 8784.7 | 8784.6 | 9032.4 | 9660.9 | 12,535.7 | 13,306.5 | 2093.3 | 1964.8 | 3337.5 | 5121.3 | 2367.9 |
| ចំណាយជាមូលធន | 2574.4 | 2853.2 | 2853.2 | 3546.9 | 3628.3 | 5567.5 | 5590.7 | 654.4 | 584.7 | 649.9 | 2083.4 | 624.5 |
| ចំណាយចរន្ត | 3809.0 | 4773.1 | 4773.1 | 5341.2 | 6188.4 | 6968.3 | 7715.8 | 1438.9 | 1380.1 | 2687.7 | 3038.0 | 1743.4 |
| បៀវត្សរ៍ | 1397.0 | 2048.8 | 2048.8 | 2170.6 | 2486.6 | 2997.3 | 3755.5 | 945.3 | 959.1 | 1281.2 | 1086.3 | 1133.1 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 927.1 | 1099.4 | 1099.4 | 1518.8 | 1586.8 | 1563.0 | 1627.0 | 194.3 | 207.1 | 544.0 | 797.1 | 259.1 |
| ចំណាយចរន្តផ្សេងទៀត | 1384.9 | 1624.8 | 1624.8 | 1651.8 | 2115.1 | 2408.0 | 2333.4 | 299.3 | 213.9 | 862.4 | 1154.6 | 351.2 |
| សមតុល្យជាទូទៅ | -1007.8 | -2795.7 | -2795.7 | -1271.4 | -1969.0 | -4280.6 | -2763.1 | 554.5 | 1336.8 | -273.8 | -2254.0 | 1164.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2055.1 | 1845.2 | 1845.2 | -2781.0 | 2457.8 | 4326.2 | 3972.1 | 368.9 | 330.1 | 297.6 | 1414.8 | 270.0 |
| ហិរញ្ញប្បទានក្នុងស្រុក | -127.0 | 938.6 | 938.6 | 2379.2 | -332.9 | 824.4 | -1428.7 | -2464.8 | -793.3 | -259.1 | -109.4 | -1471.3 |

Source: MEF website

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៨-១៦

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| (ឆ្នាំគោល ២០០៦) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 4.7 | 5.8 | 4.1 | 5.4 | 2.3 | 3.0 | 3.9 | 1.0 | 1.0 | 0.8 | 2.0 | 2.5 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 6.4 | 9.9 | 4.4 | 6.5 | 2.5 | 3.9 | 4.9 | 4.2 | 3.9 | 3.3 | 4.7 | 4.7 |
| - ដឹកជញ្ជូន | 9.1 | 5.8 | 7.0 | 6.9 | 3.3 | -0.6 | -1.0 | -10.9 | -7.9 | -9.1 | -8.9 | -6.5 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.0 | 4062.7 | 4187.1 | 4063.6 | 4039.2 | 4036.2 | 4060.4 | 4042.2 | 4056.7 | 4091.8 | 4050.9 | 4022.4 |
| រៀលក្នុង ១ បាតថៃ | 108.7 | 122.8 | 133.1 | 133.2 | 130.0 | 124.9 | 119.4 | 124.4 | 122.6 | 116.8 | 113.6 | 113.4 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.1 | 25.0 | 21.7 | 19.7 | 19.4 | 19.1 | 18.7 | 19.0 | 18.8 | 18.6 | 18.2 | 18.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 70.6 | 83.2 | 147.5 | 184.5 | 200.9 | 175.9 | 152.3 | 150.9 | 144.4 | 136.0 | 130.9 | |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3140.0 | 3262.3 | 3859.3 | 4761.2 | 4941.2 | 4852.1 | 4934.1 | 3823.4 | 4032.0 | 3840.2 | 3389.4 | 2903.8 |
| ថ្លៃសាំង (រៀល/លីត្រ) | 4004.0 | 4005.0 | 4368.1 | 5044.5 | 5312.7 | 5083.3 | 5155.7 | 3986.2 | 4189.0 | 4048.9 | 3582.5 | 3310.6 |

Sources: NIS, NBC and CDRI

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៨-១៦ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,345.6 | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 21,260.1 | 26,699.7 | 26,823.0 | 27,975.3 | 26,359.2 | 26,665.5 | 29,247.8 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 1513.3 | 1573.0 | 2778.9 | 5760.8 | 10,437.4 | 11,508.3 | 15,859.8 | 16,863.2 | 18,178.3 | 20,600.9 | 22,157.6 | 21,643.0 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2794.9 | -4359.1 | -5064 | -5666.1 | -5933.1 | -6428.8 | -7621.2 |
| ឥណទានដល់វិស័យឯកជន | 9894.1 | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 27,608.8 | 36,244.6 | 37,759.4 | 40,995.0 | 43,807.1 | 46,071.0 | 47,627.0 |
| រូបិយវត្ថុទូទៅ M2 | 11,858.9 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 32,768.4 | 42,559.5 | 43,685.2 | 46,153.7 | 46,960.1 | 48,823.1 | 50,890.9 |
| រូបិយវត្ថុ M1 | 2399.6 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4878.2 | 6308.4 | 6628.0 | 6293.1 | 6287.5 | 6741.4 | 6717.8 |
| រូបិយវត្ថុផ្សេងៗ | | | | | | | | 37,058.2 | 39,860.6 | 40,672.6 | 42,081.7 | 44,173.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 14.6 | 29.9 | 24.2 | 20.6 | 15.2 | 14.7 | 16.5 |
| រូបិយវត្ថុ M1 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 20.6 | 29.3 | 23.3 | 20.3 | 12.6 | 6.9 | 1.4 |
| រូបិយវត្ថុផ្សេងៗ | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 13.6 | 30.0 | 24.4 | 20.7 | 15.6 | 16.1 | 19.2 |

Source: National Bank of Cambodia

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2010 | 2011 | 2012 | 2013 | 2014 | 2015** | | 2016 | | 2015** | 2016 | |
| | | | | | | កុម្ភៈ | ឧសភា | កុម្ភៈ | ឧសភា | | កុម្ភៈ | ឧសភា |
| អ្នករត់ស៊ីក្លូ | 9055 | 9532 | 10,303 | 10,438 | 10,774 | 12,408 | 11,677 | 11,880 | 11,898 | 15.1 | -4.3 | 1.9 |
| អ្នកលីសែង | 9964 | 10,785 | 12,143 | 13,247 | 13,580 | 16,094 | 14,782 | 14,888 | 11,774 | 15.1 | -7.5 | -20.3 |
| អ្នកលក់បន្លែតូចតាច | 8266 | 8337 | 10,771 | 11,366 | 14,751 | 14,379 | 17,020 | 20,337 | 18,979 | 7.6 | 41.4 | 11.5 |
| អ្នករើសអេតចាយ | 6698 | 8388 | 8680 | 9819 | 9173 | 10,181 | 13,272 | 11,159 | 8737 | 34.6 | 9.6 | -34.2 |
| អ្នករត់តុភោជនីយដ្ឋាន* | 5607 | 5986 | 6111 | 6697 | 7789 | 8111 | 8188 | 7860 | 8187 | 6.9 | -3.1 | -0.01 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5691 | 5695 | 6151 | 6599 | 7514 | 7955 | 7552 | 8,484 | 7916 | 0.1 | 6.6 | 4.8 |
| កម្មកររោងចក្រកាត់ដេរ | 7746 | 8409 | 8932 | 10,161 | 11,178 | 14,644 | 14,803 | 14,937 | 13,828 | 8 | 2.0 | -6.3 |
| អ្នករត់ម៉ូតូឌុប | 10,623 | 11,568 | 12,930 | 13,450 | 13,386 | 13,939 | 13,761 | 15,526 | 15,425 | 8.3 | 11.4 | 12.1 |
| កម្មករសំណង់គ្មានជំនាញ | 8790 | 10,307 | 11,078 | 13,184 | 13,336 | 15,981 | 14,474 | 16,164 | 20,227 | 16.4 | 1.1 | 39.7 |
| កម្មករសំណង់មានជំនាញ | 11,952 | 13,159 | 13,743 | 15,442 | 17,420 | 16,336 | 18,656 | 18,853 | 21,150 | 34.1 | 15.4 | 13.4 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. **Data in November 2015 is not available.
Source: CDRI

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

**ថ្ងៃទី១៤ មិថុនា៖** លោកនាយកប្រតិបត្តិ បានចូលរួមក្នុងសិក្ខាសាលាសភាស្ដីពី "ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងថវិកាជាតិឆ្នាំ២០១៧" រៀបចំឡើងដោយ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា។ សិក្ខាសាលានេះ ជាឱកាសដ៏វិសេសសម្រាប់ធ្វើទំនាក់ទំនងជាមួយ អ្នកកសាងគោលនយោបាយជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាល និងសភាជាតិ និងដៃគូអភិវឌ្ឍន៍អន្តរជាតិផ្សេងៗ។

**ថ្ងៃទី២៧-២៩ មិថុនា៖** ក្រុមស្រាវជ្រាវផ្នែកអប់រំ និងលោកនាយកប្រតិបត្តិ បានធ្វើទស្សកិច្ចនៅកំពង់ផែស្វយ័តនិងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ វិទ្យាស្ថានបច្ចេកវិទ្យាគិរីរម្យ និងវិទ្យាស្ថានពហុបច្ចេកទេសជាតិកម្ពុជា ក្នុងគោលបំណងបង្កើតទំនាក់ទំនងការងារនាពេលអនាគត សម្រាប់កិច្ចសហការស្រាវជ្រាវពីតម្រូវការធនធានមនុស្ស និងសមត្ថភាពឡូជីស្ទិក ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា។

## ការស្រាវជ្រាវ

### ផ្នែកកសិកម្ម

ផ្នែកនេះកំពុងអនុវត្តគម្រោងស្រាវជ្រាវចំនួន ៧។ ការសិក្សាស្ដីពី *សកម្មភាពបង្កើតប្រាក់ចំណូលមិនមែនកសិកម្មនៅកម្ពុជា* ដែលទទួលមូលនិធិពី អង្គការកសិកម្ម និងស្បៀងអាហារ (FAO) បានចប់សព្វគ្រប់ ហើយរបាយការណ៍សម្រេច និងសង្ខេបគោលនយោបាយ បានបញ្ជូនទៅម្ចាស់ជំនួយរួចរាល់។ របាយការណ៍សម្រេចសម្រាប់ គម្រោង *ផលប៉ះពាល់នៃចំណាយសាធារណៈផ្នែកអប់រំទៅលើមូលធនមនុស្ស ភាពក្រីក្រ និងវិសមភាព៖ វិធីសាស្ត្រ CGE សម្រាប់កម្ពុជា* ដែលទទួលបានជំនួយទ្រទ្រង់ពី អង្គការភាពជាដៃគូសម្រាប់គោលនយោបាយសេដ្ឋកិច្ច (PEP) ក៏បានបញ្ជូនទៅម្ចាស់ជំនួយហើយដែរ។ ការវិភាគទិន្នន័យបានចប់សព្វគ្រប់ សម្រាប់គម្រោង *ផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង* ហើយបច្ចុប្បន្នក្រុមស្រាវជ្រាវកំពុងសិក្សាលើឯកសារពាក់ព័ន្ធ និងចងក្រងរបាយការណ៍។ នៅខែមិថុនា ក្រុមស្រាវជ្រាវបានរៀបចំសិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធ ដើម្បីបង្ហាញលទ្ធផលស្រាវជ្រាវនៃគម្រោង *កសិកម្មមានការស្រោចស្រពនៅកម្ពុជា* ដែលទទួលបានជំនួយទ្រទ្រង់ពី សាកលវិទ្យាល័យជាតិអូស្ត្រាលី។ អង្កេតគោលសម្រាប់គម្រោង *ការសាកល្បងគំរូបែបថ្មីនៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម នៅក្នុងគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE) របស់កម្ពុជា* ដែលទទួលមូលនិធិពី វិទ្យាស្ថានស្រាវជ្រាវពីគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) បានអនុវត្តចប់សព្វគ្រប់ ហើយទិន្នន័យស្រេចបាច់បានបញ្ជូនទៅឲ្យ IFPRI រួចរាល់។ គម្រោង *ការវិភាគពីគោលនយោបាយស្រូវ* ដែលទទួលបានមូលនិធិពី គំនិតផ្ដួចផ្ដើមផ្នែកគោលនយោបាយសាធារណៈ សម្រាប់តំបន់មេគង្គក្រោម (LMPPI) បានចាប់អនុវត្តទៅមុខ។ គម្រោងស្ដីពី *ការវាយតម្លៃចុងក្រោយលើផលប៉ះពាល់នៃកម្មវិធី HARVEST* ដែលទទួលជំនួយហិរញ្ញវត្ថុពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ក៏កំពុងដំណើរការទៅមុខដែរ។

**ផ្នែកសេដ្ឋកិច្ច**

ការសិក្សាស្ដីពី *សៀវភៅណែនាំពីសហគមន៍សេដ្ឋកិច្ចអាស៊ាន សម្រាប់សហគ្រាសអាជីវកម្មនៅកម្ពុជា* ដែលទទួលជំនួយទ្រទ្រង់ពីការិយាល័យអង្គការពលកម្មអន្តរជាតិ សម្រាប់សកម្មភាពនិយោជក (ACT/EMP) បានចប់សព្វគ្រប់។ ក្រុមស្រាវជ្រាវបានធ្វើបទបង្ហាញពី លទ្ធផលស្រាវជ្រាវសំខាន់ៗក្នុងពិធីចាប់ផ្ដើមការចេញផ្សាយសៀវភៅ និងសិក្ខាសាលានៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៦ មិថុនា និងនៅសៀមរាប កាលពីថ្ងៃទី៣០ មិថុនា។ គម្រោងស្ដីពី (១) *ការកំណត់ច្រកផ្ញើប្រាក់ និងការគ្រប់គ្រងប្រាក់ផ្ញើមកផ្ទះនៅកម្ពុជា* (២) *ទំនាក់ទំនងរវាងគោលនយោបាយសាធារណៈរបស់ប្រទេសជាដៃគូ ចំណាកស្រុក និងការអភិវឌ្ឍ៖ករណីសិក្សា និងមតិមួយចំនួនផ្នែកគោលនយោបាយ* និង (៣) *ការពិនិត្យឡើងវិញលើការងារមិនទាន់ចប់៖ កត្តាកំណត់នៃលទ្ធភាពទទួលបានឥណទាន និងផលប៉ះពាល់ទៅលើផលិតកម្មកសិកម្ម និងការប្រើប្រាស់ដីនៅជនបទកម្ពុជា* ជិតបានចប់សព្វគ្រប់ហើយ។

គម្រោងស្ដីពី *ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការវិវត្តក្នុងទីផ្សារពលកម្ម៖ ការពិសោធតាមវិធីចៃដន្យក្នុងចំណោមជនកម្ពុជាទើបពេញវ័យ* នៅក្រោមកម្មវិធី បណ្ដាញស្រាវជ្រាវមហាអនុតំបន់មេគង្គ (GMS-Net) ដែលទទួលមូលនិធិពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា កំពុងជឿនលឿនទៅមុខៗ។ ក្រុមស្រាវជ្រាវជ្រើសរើសអ្នកចូលរួមក្នុងគម្រោងបាន ២០រូប សម្រាប់ការបណ្ដុះបណ្ដាលជំនាញនៅ អង្គការដើម្បីភាពញញឹមនៃកុមារ (PSE) ហើយបច្ចុប្បន្នកំពុងជ្រើសរើសក្រុមទី២ សម្រាប់ការបណ្ដុះបណ្ដាលជំនាញ។

សំណើស្រាវជ្រាវស្ដីពី *ការពង្រឹងការស្រាវជ្រាវ និងកិច្ចសន្ទនាផ្នែកគោលនយោបាយមេគង្គ-ចិន* ដែលក្រុមស្រាវជ្រាវផ្នែកសេដ្ឋកិច្ច បានដាក់ទៅម្ចាស់ជំនួយក្នុងក្របខ័ណ្ឌសហប្រតិបត្តិការ និងកិច្ចសន្ទនាទន្លេមេគង្គ ត្រូវបានជ្រើសរើស និងផ្ដល់ជំនួយជាអំណោយហិរញ្ញវត្ថុ ៥០០.០០០ដុល្លារ ដោយក្រសួងការបរទេស នៃសាធារណៈរដ្ឋប្រជាមានិតចិន។ កម្មវិធីនេះ មានវត្ថុបំណងចម្បងៗពីរគឺ៖ (១) ធ្វើការស្រាវជ្រាវមានភាពពាក់ព័ន្ធល្អផ្នែកគោលនយោបាយ សម្រាប់ប្រទេសទាំងអស់ដែលចូលរួមក្នុងក្របខ័ណ្ឌសហប្រតិបត្តិការ និងកិច្ចសន្ទនាទន្លេមេគង្គ និង (២) ពង្រឹងការតភ្ជាប់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ តាមរយៈការស្រាវជ្រាវរួមគ្នា និងកិច្ចសន្ទនាផ្នែកគោលនយោបាយមេគង្គ-ចិន។ កម្មវិធីនេះមាន ២សមាសភាគគឺ ការស្រាវជ្រាវ និង ការសន្ទនាផ្នែកគោលនយោបាយ ហើយគ្រោងដំណើរការក្នុងរយៈពេល ២ឆ្នាំ ពីថ្ងៃទី១ កក្កដា ២០១៦ ដល់ ៣១ កក្កដា ២០១៨។

**ផ្នែកអប់រំ**

សិក្ខាសាលាបំផុសគំនិតស្ដីពី "ការស្រាវជ្រាវ និងឥទ្ធិពលលើគោលនយោបាយឧត្ដមសិក្សានៅកម្ពុជា" ក្រោមកិច្ចសហការជាដៃគូរវាង CDRI នាយកដ្ឋានឧត្ដមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការបរទេសនៃប្រទេសអូស្ត្រាលី (DFAT) បានរៀបចំឡើងនៅ CDRI កាលពីខែមេសាកន្លងទៅ។ សិក្ខាសាលានេះ បង្កើតឡើងសម្រាប់ការត្រៀមចាប់ផ្ដើមគម្រោងរយៈពេល៣ឆ្នាំនិងពិគ្រោះយោបល់ស្ដីពីអាទិភាពនានានៃគម្រោង និងភាពពាក់ព័ន្ធល្អជាមួយនឹង កំណែទម្រង់គោលនយោបាយឧត្ដមសិក្សា។

ក្នុងខែមេសានេះដែរ ក្រុមស្រាវជ្រាវផ្នែកអប់រំ បានទទួលគណៈប្រតិភូមកពីសាកលវិទ្យាល័យ South University of Science and Technology of China និង មជ្ឈមណ្ឌល UNESCO International Centre for Higher Education Innovation (ICHEI)។ ភាគីទាំងសងខាង បានពិភាក្សាពីបញ្ហាជុំវិញឧត្ដមសិក្សានៅចិន និងកម្ពុជា និងលទ្ធភាពរួមសហការជាដៃគូធ្វើការស្រាវជ្រាវរួមគ្នា។ អនុស្សារណៈយោគយល់មួយ ត្រូវបានរៀបចំឡើងបន្ទាប់ពីនោះ សម្រាប់ការចុះហត្ថលេខានៅពេលសមគួរណាមួយនាថ្ងៃខាងមុខ ដើម្បីញ៉ាំងឲ្យការស្រាវជ្រាវរួមគ្នាអាចអនុវត្តទៅបាន។

សិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពី "វិធីសាស្ត្រស្រាវជ្រាវ" មួយស៊េរី ត្រូវបានរៀបចំឡើងក្នុងលក្ខណៈជាផ្នែកមួយនៃកម្មវិធីស្រាវជ្រាវគោលនយោបាយឧត្ដមសិក្សា ដោយទទួលបានមូលនិធិពី DFAT។ ការបណ្ដុះបណ្ដាលមាន ៨វគ្គនេះ បានដំណើរការនៅខែមេសា និងមិថុនា ដោយមានបណ្ឌិត អ៊ិន យាង សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Northern Illinois University ជាអ្នកធ្វើបទបង្ហាញ។ អ្នកចូលរួម ១៥នាក់ មកពី ៥ផ្នែកស្រាវជ្រាវ ទទួលបានអត្ថប្រយោជន៍ពី ការបណ្ដុះបណ្ដាលផ្អែកលើបទពិសោធន៍ស្រាវជ្រាវជាក់ស្ដែងនេះ។

អត្ថបទ២ ស្ដីពី "វិទ្យាល័យនៅកម្ពុជា៖ ចន្លោះខ្វះខាតផ្នែកស្រាវជ្រាវ"និង"ការចូលរួមរបស់សិស្សក្នុងការអប់រំមុខវិជ្ជាSTEM៖ ការពិនិត្យជាសាកល និងផលពាក់ព័ន្ធសម្រាប់កម្ពុជា" កំពុងរៀបចំឡើងសម្រាប់ការបោះពុម្ពផ្សាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ប្រចាំត្រីមាស។

**ផ្នែកបរិស្ថាន**

ឯកសារពិភាក្សាក្រោមចំណងជើង "ធនធានទ្រព្យរួម និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ៖ ការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍នៅកម្ពុជា" កំពុងរៀបចំសម្រាប់ការបោះពុម្ពផ្សាយ។ ឯកសារនេះបង្ហាញពីលទ្ធផលស្រាវជ្រាវនៃគម្រោងទទួលបានមូលនិធិពី Sida ដែលមានគោលដៅពិនិត្យអង្កេតពីវិធីពង្រឹងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ដើម្បីរក្សាចីរភាព ឬលើកកម្ពស់ការរួមចំណែករបស់វា ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ភាពធន់ និងសន្តិសុខស្បៀង។ របាយការណ៍សំយោគនូវឯកសារពិភាក្សាចំនួន ៥ ក្រោមកម្មវិធីរយៈពេល ៥ឆ្នាំ របស់ Sida ក៏កំពុងចងក្រងបង្ហើយដែរ។ ប្រធានបទនៃរបាយការណ៍សំយោគនោះ រួមមាន ការចិញ្ចឹមជីវិត និងកំណើនសម្រាប់គ្រប់គ្នា បញ្ហាយេនឌ័រក្នុងអភិបាលកិច្ចទឹក សមត្ថភាពបន្សាំ កសិកម្មវៃឆ្លាតតាមអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍។ គម្រោងស្ដីពី *បញ្ហាយេនឌ័រក្នុងការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិស្ថាន*

*នៅកម្ពុជា* ដែលទទួលបានមូលនិធិពី USAID ក្រោមគម្រោងភាពជាដៃគូតំបន់មេគង្គដើម្បីបរិស្ថាន បានចាប់ដំណើរការ ហើយបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងពិនិត្យព័ត៌មានពាក់ព័ន្ធទាំងឡាយ ដើម្បីរៀបចំការចុះសិក្សាដល់កន្លែងនៅខេត្តស្ទឹងត្រែង និងកំពត នៅខែមិថុនា និង កក្កដា។

## ផ្នែកអភិបាលកិច្ច

ក្រុមស្រាវជ្រាវ បាននិងកំពុងអនុវត្តគម្រោងចំនួន ៧។ ក្នុងគម្រោង *អភិបាលកិច្ចទឹកល្អនៅតំបន់មេគង្គ* មានឯកសារពិភាក្សា ២ កំពុងរៀបចំចងក្រងឡើងគឺ (១) ការយល់ឃើញនៅមូលដ្ឋានអំពីការឲ្យទៅតាំងទីលំនៅក្នុងកន្លែងថ្មី នៅតំបន់ទំនប់ទឹក និង (២) ការស្រាវជ្រាវដើម្បីធ្វើសកម្មភាពដោយមានការចូលរួមពីមូលដ្ឋាន ស្ដីពី ការចូលរួមរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចតំបន់មេគង្គ។ ក្រុមស្រាវជ្រាវបានចងក្រងរួចរាល់នូវ របាយការណ៍ប្រើរូបថតដោយមានការចូលរួមពីមូលដ្ឋាន ដែលបង្ហាញពីផលប៉ះពាល់នៃការអភិវឌ្ឍវារីអគ្គិសនី ទៅលើជីវភាពរស់នៅក្នុងមូលដ្ឋាន ផ្អែកលើការយល់ឃើញរបស់សហគមន៍មូលដ្ឋាន។ រូបថតរបស់អ្នកចូលរួម គឺជាសម្លេងបន្ថែមមួយទៀត ដែលជួយឲ្យពួកគេអាចបង្ហាញពីគំនិត និងយោបល់ផ្ទាល់ខ្លួន និងឲ្យអ្នកស្រាវជ្រាវបានយល់ដឹងកាន់តែស៊ីជម្រៅពី បញ្ហាដែលអ្នកស្រុកកំពុងជួបប្រទះ។ ក្នុងកម្មវិធីរបស់ Sida នេះ ក្រុមស្រាវជ្រាវកំពុងបង្ហើយឯកសារពិភាក្សា ៣ ដែលពិនិត្យពី ការជឿនលឿនទៅមុខ និងបញ្ហាប្រឈម ក្នុងការផ្ទេរមុខងារការគ្រប់គ្រងសំណល់រឹង ការប្រើប្រាស់មូលនិធិក្រុងស្រុក និងការផ្ទេរមុខងារដែលអាចកើតមានឡើងសម្រាប់ការអប់រំកម្រិតបឋម។ ក្រុមស្រាវជ្រាវបានចាប់ផ្ដើមរៀបរៀងសៀវភៅមួយក្រោមចំណងជើងថា "ផលប៉ះពាល់កំពុងលេចចេញមកនៃ ប្រជាជនកម្ពុជាវ័យក្មេងជំនាន់ថ្មី ទៅលើសង្គម និងបញ្ហានយោបាយ"។ សៀវភៅនេះមានគោលដៅប្រមូលផ្ដុំនូវ ការសិក្សាមានស្រាប់អនុវត្តជាចម្បងដោយអ្នកស្រាវជ្រាវកម្ពុជា ស្ដីពីយុវជនកម្ពុជា។ សម្រាប់អ្នកចូលរួមចងក្រងសៀវភៅ និងអ្នកស្រាវជ្រាវ មានការរៀបចំសិក្ខាសាលារយៈពេល ១ថ្ងៃ នៅពាក់កណ្ដាលខែមិថុនា ដើម្បីពិភាក្សាពីគោលគំនិតធំៗ សំណួរស្រាវជ្រាវសំខាន់ៗ និងលទ្ធផលស្រាវជ្រាវពីដំបូងៗ បានពីអ្នករួមចំណែកចងក្រងជំពូកនីមួយៗនៃសៀវភៅនេះ។

ទាក់ទងនឹងការអភិវឌ្ឍសមត្ថភាព ក្រុមស្រាវជ្រាវបានចូលរួមសិក្ខាសាលារយៈពេល ១ថ្ងៃ ស្ដីពី សំណេរសម្រាប់ការបោះពុម្ពផ្សាយ ដោយមានបណ្ឌិត Caroline Hughes ទីប្រឹក្សាស្រាវជ្រាវ និងសាស្ត្រាចារ្យផ្នែកការសិក្សាពីសន្តិភាព នៃសាកលវិទ្យាល័យ Bradford មកធ្វើបទបង្ហាញពន្យល់។ សមាជិកខ្លះនៃក្រុមស្រាវជ្រាវនេះ ក៏បានចូលរួមក្នុងកម្មវិធីបណ្ដុះបណ្ដាលរយៈពេល ៨សប្ដាហ៍ ស្ដីពី វិធីសាស្ត្រ និងការរចនារៀបចំការស្រាវជ្រាវ ដោយមាន បណ្ឌិត អ៊ុន យៀង ទីប្រឹក្សាស្រាវជ្រាវ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Illinois មកធ្វើបទបង្ហាញពន្យល់។

## Cambodia Development Review—2016 Subscription Rates

**Domestic subscription (individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic subscription (discount price for bulk orders—five copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Unit at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

**ថ្ងៃទី១ មេសា៖** ក្នុងឱកាសជួបសំណេះសំណាលសម្តែងការគួរសមមួយ លោកនាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានជម្រាបជូនលោកស្រី Ruth Steward អនុប្រធានបេសកកម្មថ្មី នៃស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា អំពី បេសកកម្ម និងសកម្មភាព CDRI និងការជឿនលឿនទៅមុខនៃ កម្មវិធីស្រាវជ្រាវផ្នែកគោលនយោបាយអប់រំ ដែលទទួលបានមូលនិធិពី ក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី (DFAT)។

**ថ្ងៃទី៤ មេសា៖** សិក្ខាសាលាបំផុសគំនិតមួយស្តីពី "ការស្រាវជ្រាវ និងការជះឥទ្ធិពលលើគោលនយោបាយសម្រាប់ឧត្តមសិក្សានៅកម្ពុជា" បានប្រព្រឹត្តទៅដោយមានការចូលរួមពីលោកស្រី Sarah Toh មកពីស្ថានទូតអូស្ត្រាលី, ឯកឧត្តម ម៉ក់ ងយ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា, អ្នកតំណាងមកពី ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (Sida) និងអ្នកសិក្សាអប់រំមកពី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិអប់រំ និង សាកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ។ សិក្ខាសាលានេះសំដៅ បង្កើតកិច្ចសន្ទនាមួយ ដើម្បីកំណត់ទិសដៅនៃការស្រាវជ្រាវសំខាន់ៗសម្រាប់កម្មវិធីផ្នែកអប់រំរបស់ CDRI។

**ថ្ងៃទី៧ មេសា៖** លោកនាយកប្រតិបត្តិ បានចូលរួមសិក្ខាសាលាសន្ទនាផ្នែកគោលនយោបាយ រយៈពេល ៣ថ្ងៃមួយ ដើម្បីពិភាក្សាពី វិធីលើកទឹកចិត្តនារីឲ្យចូលរួមក្នុងការអប់រំ STEM និងបញ្ជ្រាបការអប់រំ STEM មានការគិតគូរផ្នែកយេនឌ័រ ទៅក្នុងវគ្គបណ្តុះបណ្តាលគ្រូ ការរៀនសូត្រ និង សម្ភារបង្រៀន។ សិក្ខាសាលានេះ សហការរៀបចំឡើងដោយ ក្រសួងអប់រំ យុវជន និងកីឡា (MOEYS) និង អង្គការ UNESCO ក្នុងក្របខ័ណ្ឌនៃកម្មវិធីសហប្រតិបត្តិការ ម៉ាឡេស៊ី-UNESCO ស្តីពី "ការពង្រឹងកម្មវិធីសិក្សា STEM សម្រាប់នារីនៅទ្វីបអាហ្វ្រិក អាស៊ី និងប៉ាស៊ីហ្វិក"។ សិក្ខាសាលានេះជាឱកាសមួយសម្រាប់ចែករំលែកការស្រាវជ្រាវរបស់ CDRI លើការអប់រំ STEM ជាមួយមន្ត្រីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងមជ្ឈដ្ឋានសិក្សាអប់រំ។

**ថ្ងៃទី៥ ឧសភា៖** បុគ្គលិកផ្នែកសេដ្ឋកិច្ច និងលោកនាយកប្រតិបត្តិ បានជួបជាមួយ លោក Takashi Shimada ស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានអភិវឌ្ឍន៍តំបន់ឆ្នេរក្រៅប្រទេសនៃប្រទេសជប៉ុន ដើម្បីផ្លាស់ប្តូរមតិយោបល់ និងព័ត៌មានស្តីពី គម្រោងស្រាវជ្រាវលើការតភ្ជាប់ផ្លូវសមុទ្រនៅអាស៊ីអាគ្នេយ៍។

**ថ្ងៃទី១០-១១ ឧសភា៖** លោកនាយកប្រតិបត្តិ បានចូលរួមក្នុងវេទិកាក្រុមផ្តល់គំនិតអន្តរជាតិលើកទី១ នៃផ្លូវសូត្រសមុទ្រសតវត្សរ៍ទី២១ រៀបចំឡើងនៅទីក្រុង Guangzhou ដោយមជ្ឈមណ្ឌលសហការបែបថ្មី សម្រាប់ការសិក្សាពីផ្លូវសូត្រសមុទ្រសតវត្សរ៍ទី២១ នៃសាកលវិទ្យាល័យ Guangdong ផ្នែកសិក្សាបរទេស។ វិទ្យាស្ថាន CDRI បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់មួយ ជាមួយមជ្ឈមណ្ឌលនេះ ដើម្បីផ្តល់ភាពផ្លូវការដល់សកម្មភាពសហការស្រាវជ្រាវផ្សេងៗទៅអនាគត។

**ថ្ងៃទី៣១ ឧសភា៖** ក្នុងកិច្ចជួបសំណេះសំណាលបង្ហាញសមាសភាពគ្នាមួយ ក្រុមអ្នកស្រាវជ្រាវជាន់ខ្ពស់ និងអ្នកគ្រប់គ្រងនៃវិទ្យាស្ថាន CDRI បានជួបជាមួយលោកស្រី Leonie Lethbridge ជាអគ្គនាយកនៃធនាគារ ANZ Royal ដើម្បីផ្តល់ព័ត៌មានពីកម្មវិធីស្រាវជ្រាវ និងសកម្មភាព CDRI និងពិភាក្សាពីកិច្ចសហការជាដៃគូរវាង CDRI និង ANZ ដើម្បីរៀបចំសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំ។

**ថ្ងៃទី៩-១១ មិថុនា៖** លោកនាយកប្រតិបត្តិនៃ CDRI បានចូលរួមពិធីចាប់ដំណើរការ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ឧត្តមសិក្សាបែបថ្មី (ICHEI) នៃសាកលវិទ្យាល័យភូមិភាគខាងត្បូងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅទីក្រុង Shenzhen ប្រទេសចិន។ CDRI និង ICHEI បានព្រមព្រៀងចុះហត្ថលេខាលើអនុស្សារណៈយោគយល់មួយ។ លោកនាយកប្រតិបត្តិក៏បានទទួលការអញ្ជើញឲ្យចូលរួមក្នុងក្រុមប្រឹក្សានៃ ICHEI និងបានចូលរួមក្នុងកិច្ចប្រជុំអន្តរជាតិលើការអប់រំពីគំនិតបែបថ្មី និងសហគ្រិនភាព។

*តទៅទំព័រ ២១*

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា
*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*
ឆ្នាំទី២០ លេខ២ ខែមិថុនា ឆ្នាំ២០១៦

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវការវាយតម្លៃឯករាជ្យពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ Fax (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសម្រួល: យូ សិទ្ធិរិទ្ធ
កែសម្រួលផលិតកម្ម: អ៊ុំ ចាន់ថា

សហគ្រាសបោះពុម្ព Invent Cambodia, រូបភាពទំព័រមុខ: យកពី Google

© រក្សាសិទ្ធិ ២០១៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh